# កូនស្រីដ៏ស្រស់ស្អាតរបស់ប៉ុល ពត

នៅក្នុងប្រទេសកម្ពុជា ប្រជាជនស៊ាំនឹងរឿងខ្មោចទៅហើយ។ ខ្មោចទិញកាសែត។ ខ្មោចគ្រប់គ្រងផ្ទះ រឺអចលនទ្រព្យនានា។

កាលពីប៉ុន្មានឆ្នាំមុន មានពាក្យចចាមអារ៉ាមថា មានផ្ទះខ្មោចមួយនៅក្នុងទីក្រុងភ្នំពេញ ឯចុងបឹងត្របែកតាមមហាវិថីព្រះមុនីវង្ស។ របបខ្មែរក្រហមបានសម្លាប់គ្រួសារទាំងមូលនៅក្នុងផ្ទះនោះ ហើយគ្មាននរណាម្នាក់ទទួលមរតកផ្ទះនោះទេ។ មនុស្សម្នាដើរទៅមកកាត់អគារនោះ ថែមទាំងវាយបន្ទះក្តារបិទ បង្អួចទ្វារទាំងអស់។ គេឮសម្លេងយំខ្សឹកខ្សួលពីខាងក្នុង។

បន្ទាប់មក មានញាតិសាច់ឆ្ងាយម្នាក់មកពីប្រទេសអាមេរិក។ នាងបានធ្វើការស្រាវជ្រាវ ហើយក៏អាចបញ្ជាក់បានថា គឺជាសមាជិកដែលនៅរស់ចុងក្រោយបង្អស់នៃគ្រួសារដែលមានសមាជិកមិនលើសពីបីនាក់នេះ។ នាងក៏លក់ផ្ទះនេះឲ្យទៅឈ្មួញចិនម្នាក់ភ្លាម។ គាត់បានប្រែក្លាយជាន់ផ្ទាល់ដីទៅជាហាងថតចម្លងឯកសារ។

ម៉ាស៊ីនថតចម្លងទាំងនោះស្រាប់តែបោះពុម្ភរូបភាពរបស់ម្ចាស់ផ្ទះដើមទាំងអស់។

មុនដំបូង រូបថតសខ្មៅរបស់អ្នកធ្វើការអង្គការ និងមន្ត្រីរាជការ បានលេចចេញឡើងនៅក្នុងថតឯកសារ។ ឪពុកគ្រួសារដែលគេសម្លាប់ចោលនោះធ្លាប់ធ្វើជាមេធាវី។ គាត់បានសម្លក់យ៉ាងសាហាវឃោរឃៅហាក់ដូចជាទាមទារអ្វីមួយអញ្ចឹង។ នៅក្នុងរូបថតផ្សេងទៀត ឃើញមានកូនស្រីដ៏ស្រស់ស្អាតរបស់គាត់កំពុងតែអោបក្រសោបគ្នាទាំងទុក្ខសោក។ ចំនែកឯផ្ទៃខាងក្រោយនៃរូបភាពព្រាលៗដូចជាអ័ព្ទ។

នាយប់មួយ ម្ចាស់ហាងនោះបានឮសម្លេងអ្វីមួយ ហើយក៏ប្រញាប់ចុះមកមើល ស្រាប់តែឃើញម៉ាស៊ីនថតចម្លងទាំងប្រាំកំពុងតែបោះពុម្ពរូបភាពមួយហើយមួយទៀតជាបន្តបន្ទាប់គ្នា៖ មានតាំងពីនិស្សិតមហាវិទ្យាល័យ ស្ត្រីចំនាស់ៗ ឪពុកម្តាយជាមួយនឹងកូនមួយចង្វាយៗ រឺក៏ទាហានរាជការស្លៀកពាក់ឯកសណ្ឋាន។ គាត់ក៏ចុចប៊ូតុងពណ៌បៃតងឲ្យវាបិទ ប៉ុន្តែម៉ាស៊ីនទាំងនោះនៅតែដំណើរការ។

គាត់ក៏សាកដកឌុយទាំងអស់ចេញ តែម៉ាស៊ីនទាំងនោះនៅតែបញ្ចេញរូបមុខមនុស្សម្តងមួយៗឥតអាក់។ រូបស្ត្រីបួងសក់ រឺក៏រូបក្មេងៗពាក់វ៉ែនតាសម្លឹងមើលមកយ៉ាងស្រងូតស្រងាត់នៅក្នុងក្រដាសទាំងអស់នោះ។ ពួកគេហាក់ដូចជាកំពុងតែនឹកទៅដល់ផ្ទះកាលពីសម័យហុកសិប គឺជាពេលដែលទីក្រុងភ្នំពេញជាទីក្រុងដ៏ស្រស់ស្អាតបំផុតនៅក្នុងអាស៊ីអាគ្នេយ៍។

និពន្ធដោយ៖ ជីអូហ្វ រីមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ *F*

ដំណឹងនេះក៏ផ្សព្វផ្សាយចេញទៅក្រៅ។ អ្នកផងទាំងពួងក៏ចាប់ផ្តើមម្នីម្នាមកកាន់ហាងនោះ ដើម្បីស្វែងរកសាច់ញាតិដែលចែកឋានទៅ។ ស្ត្រីខ្លះពេលមើលរូបហើយក៏ស្រែកថា "នេះហើយជាម្តាយរបស់ខ្ញុំ! ខ្ញុំគ្មានរូបថតគាត់សូម្បីតែមួយសន្លឹក!" ហើយពួកគាត់ក៏ទ្រហោយំ រួចយកក្រដាស A4 ជោកដោយទឹកភ្នែកមកផ្ទាប់នឹងដើមទ្រូង។ ក្រដាសនោះក៏ទក់ និងសើម ហាក់បីដូចជាអ្នកនៅក្នុងរូបថតក៏យំដែរ។

មិនយូរប៉ុន្មាន មនុស្សមួយហ្វូងបានមកផ្តុំគ្នានៅក្រៅហាងនោះជារៀងរាល់ព្រឹកដើម្បីរកមើលរូបថតទើបបោះពុម្ពថ្មីៗ។ ដោយអស់សង្ឃឹមនឹងធ្វើអ្វីមិនកើត ម្ចាស់ហាងក៏ប្រកាសថារូបថតដែលបោះពុម្ពបានពីមួយថ្ងៃទៅមួយថ្ងៃនឹងបញ្ជូនទៅកាន់ទស្សនាវដ្តី *ស្វែងរកការពិត* ។

ក្រោយមក នាព្រឹកមួយ ពេលគាត់ព្យាយាមបើកទ្វារហាង ស្រាប់តែឃើញថាគាំងបើកមិនរួច។ គាត់ក៏ដើរក្រវែលទៅមុខអគារនោះ ហើយបើកបង្អួចមើល។

ហាងនោះត្រូវក្រដាសបោះពុម្ពគ្របដណ្តប់ជិតតាំងពីពិតានរហូតដល់ដី។ ជាន់ផ្ទាល់ដីគ្មានបង្អួចឡើយ ដូច្នេះក្រដាសទាំងនោះច្បាស់ជាមកពីខាងក្នុងនោះឯង។ ម្ចាស់ហាងទាញក្រដាសមួយសន្លឹកមកមើល ហើយក៏ដួលខ្លួនព្រូសទៅលើដី ដោយនឹកស្មានមិនដល់។ រូបភាពដដែលៗស្ថិតនៅគ្រប់ទំព័រក្រដាស។

គាត់បានបំផ្លាញម៉ាស៊ីនថតចម្លងទាំងនោះ ព្រមទាំងលក់ផ្ទះនោះភ្លាម។ ម្ចាស់ផ្ទះថ្មីពេញចិត្តនឹងពាក្យចចាមអារ៉ាមរឿងខ្មោចនេះ ព្រោះកុំឲ្យអ្នកផងមករំខាន ។ ផ្លាកសម្រាប់លក់ត្រូវគេទុកព្យួរចោលនៅជាន់ទីពីរ។

បើតាមការប្រមើលមើលទៅ មានខ្មោចទិញផ្ទះនេះមែន។

នេះគឺជារឿងប្រឌិតទាំងស្រុងអំពីមនុស្សម្នាក់ដែលច្បាស់ជាមានជីវិត។

កូនស្រីតែមួយគត់របស់ប៉ុលពតកើតនៅឆ្នាំ ១៩៨៦ ។ នាងឈ្មោះសិដ្ឋ ហើយនៅឆ្នាំ ២០០៤ នាងមានអាយុ ១៨ ឆ្នាំហើយ។

សិដ្ឋចូលចិត្តម៉ាស៊ីនត្រជាក់ និងយានយន្តទំនើបៗ។ នាងចង់សក់ទីទុយហើយមានចោះក្រវិលនៅពីលើភ្នែកនាងម្ខាង។ ខោខូវប៊យរបស់នាងត្រូវបានគេកាត់ និងច្នៃយ៉ាងល្អប្រណិត។ អាវយឺតពណ៌ផ្កាឈូករបស់នាងមានពាក្យស្លោកជាភាសាអង់គ្លេសថា៖ CARE KOOKY. PINK MOLL.

សិដ្ឋរស់នៅដូចជាតួកុនក្នុងរឿងថៃអញ្ចឹង ចង់ធ្វើអ្វីក៏បានស្រេចនឹងចិត្ត។ មាត់នាងលាបក្រែមឡើងរលោង ឯសក់កក់សាប៊ូសាន់ស៊ីល។ មានច្បាប់ប្រាំបួនយ៉ាងដែលជួយឲ្យនាងចៀសចេញពីរឿងមិនសប្បាយចិត្តទាំងឡាយ។

1. កុំគិតពីរឿងអតីតកាល រឺក៏រឿងនយោបាយ។
2. កុំរវីរវល់នឹងខ្មោច។ ពួកគេមិនអាចធ្វើបាបយើងបានទេ។
3. កុំទៅសាលាឲ្យសោះ សូវជួលគ្រូបង្រៀន។ កុំធ្វើកិច្ចការផ្ទះ នាំតែរំខាន។
4. ត្រូវចេញទៅណាមកណាក្នុងឡាន ម៉ាសេដែសរី ប៊ីអិមដាប់ប៊ែលយូ ។
5. គេចចេញពីប្រុសៗខ្មែរដែលស្លៀកពាក់ហ៊ីហា។ ពួកគេច្រើនតែជាកូនប្រុសរបស់ឧត្តមសេនីយ៍ដែលមានប្រមាណជាង ២៥០ ០០០ នាក់នៅក្នុងប្រទេស។ កូនប្រុសរបស់ពួកលោកធំទាំងនេះធ្វើអ្វីមិនខ្លាចច្បាប់ទេ។
6. គេចចេញពីប្រុសទាំងឡាយណាដែលដុះក្បាលពោះ។ ពួកគេច្បាស់ជាញ៉ាំនំឆ្ងាញ់ដេកស្រួល អញ្ចឹងច្បាស់ជាពួករលួយមិនលែងទេ។
7. ជៀសឲ្យឆ្ងាយពីមនុស្សជិះម៉ូតូ តូយ៉ូតា រីវា រី ហុងដា ឌ្រីម ។
8. កុំឆ្លើយតបនឹងសំបុត្រ រឺទូរស័ព្ទ។
9. កុំចងមិត្តនឹងនរណាម្នាក់ឲ្យសោះ។

នៅមានច្បាប់ទីដប់មួយទៀត ប៉ុន្តែមិនបាច់និយាយក៏ដឹងដែរ។

សំបកផ្លែឈើស្អុយរលួយ និងភក់ជ្រាំ មិនដែលប្រឡាក់ស្បែកជើងកីឡារបស់សិដ្ឋម្តងណាឡើយ។ អ្នកសុំទានពិការមិនដែលសុំប្រាក់របស់នាងទេ។ ជីវិតរបស់នាងចាប់ផ្តើមពីម្សិលមិញ ហើយថ្ងៃនេះក៏ដូចគ្នាដែរ។

ជារៀងរាល់ថ្ងៃ អ្នកបើកឡានរបស់នាងជូននាងទៅផ្សារសូរិយាថ្មី។ វាស្ទើរតែជាកន្លែងតែមួយគត់ដែលសិដ្ឋទៅ។ ពណ៌ទឹកប្រាក់នៃផ្សារសូរិយាឡើងទៅច្រើនជាន់ខាងលើ រហូតមកដល់ដោមកញ្ចក់មូលមួយ។

សិដ្ឋចូលចិត្តចូលតាមច្រកផ្លូវទី ១៤២ ។ រនាំងបាំងសាចពណ៌បៃតងនៅច្រកផ្លូវនោះ ធ្វើឲ្យអ្នករាល់គ្នាមើលទៅដូចជាធ្វើពីមាសអញ្ចឹង។ ច្រកទ្វារនោះចូលត្រង់ទៅក្នុងបណ្តាតូបលក់គ្រឿងអលង្ការត្រជាក់ដូចទឹកកក ក្រាលដោយឥដ្ឋពណ៌សខ្មៅដែលត្រូវបានដុសខាត់យ៉ាងរលោងព្រាល់។ តូបនីមួយៗមានព្យួរខ្សែក និងក្រវិលភ្លឺចិញ្ចែងចិញ្ចាច។

និពន្ធដោយ៖ ជីអូហ្វ រ៉ៃមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ *F*

សិដ្ឋចូលចិត្តវត្ថុភ្លឺតូចៗ ដែលមិនធ្វើឲ្យនាងនឹកឃើញដល់រឿងអតីត។ នាងស្អប់នយោបាយណាស់។ នាងមិនព្រមស្ដាប់ព័ត៌មានឡើយ។ កូនស្រីដ៏ស្រស់ស្អាតរបស់ប៉ុល ពតម្នាក់នេះចង់ឲ្យតែអ្នកដឹកនាំសព្វថ្ងៃសំដែងអាកប្បកិរិយាគួរឲ្យគោរព ដូចជាឪពុករបស់នាងដែរ។ពោលគឺចំពោះរូបនាង។

នាងនៅចាំសំឡេងដ៏ស្រទន់របស់ឪពុកនាង។ នាងនឹកឃើញដល់កាលពីនាងអង្គុយលើភ្លៅគាត់ក្នុងបន្ទាយហ៊ុមព័ទ្ធដោយព្រៃជុំវិញ និងត្រូវមូសខាំរញ៉េរញ៉ៃ។ ឲ្យតែរំលឹកដល់ជម្ងឺគ្រុនចាញ់ធ្វើឲ្យនាងព្រឺដល់ឆ្អឹងខ្នង។ ឥឡូវ នាងចាត់ទុកព្រៃព្រឹក្សថាជាភារៈគួរឲ្យខ្ពើមរអើម ពោរពេញដោយជម្ងឺ និងការឈឺចាប់។ គ្រាន់តែស្រមោលដើមឈើប៉ះលើស្បែកនាងបន្តិច ក៏ធ្វើឲ្យនាងចង់ក្អួតទៅហើយ ចំនែកឯក្លិនធូលីដី រឺស្លឹកឈើជ្រុះក៏ធ្វើឲ្យនាងយកដៃខ្ទប់មាត់ដែរ។ នាងមិនធ្លាប់ទៅលេងអង្គរវត្តទេ សូម្បីតែអានអំពីអង្គរវត្តក៏ទេដែរ។

សិដ្ឋដើរទិញអីវ៉ាន់រហូត។ អ្នកបើកបររបស់នាងត្រូវរដ្ឋាភិបាលជួលឲ្យមកធ្វើការ ហើយតែងតែស្ពាយ អាកា ៤៧ ជាប់ខ្លួនជានិច្ច ប៉ុន្តែប្រពន្ធរបស់គាត់ ដែលត្រូវជាអ្នកមើលថែទាំផ្ទះនោះ គ្មានដឹងថាសិដ្ឋជានរណាឡើយ។ ផ្ទះសិដ្ឋពោរពេញទៅដោយគ្រឿងសង្ហារិមល្អប្រណីតធ្វើពីឈើម៉ៃស័កនិងមានតាំងពី អាយផត អិចស៍បក់ ថែមទាំងកញ្ចក់អេក្រង់ផ្លាស្មា។

សូមចងចាំថាសម្ដីគ្រប់ម៉ាត់នៅក្នុងរឿននេះគ្រាន់តែជាការប្រឌិតប៉ុណ្ណោះ។ បច្ចុប្បន្ន ប៉ុលពតគឺជាជនកុម្មុយនីសនិយមម្នាក់ ដែលគ្មានទទួលបានប្រាក់មួយកាក់មួយសេនពីការត្រួតត្រាប្រទេសកម្ពុជា។ ទោះបីជាយ៉ាងណាក្ដី ប្រាក់របបយ៉ាងក្រាស់ក្រៃលរមែងបញ្ចូលមកឲ្យសិដ្ឋជារៀងរាល់ខែពីគណនីមួយក្នុងប្រទេសស្វីស។

គ្មានអីអាចពាល់សិដ្ឋបានទេ រហូតដល់ថ្ងៃមួយដែលនាងលង់ស្នេហ៍អាជីវករក្រុមហ៊ុនទូរស័ព្ទហេឡូ។

អ្នកអានដែលជាជនជាតិខ្មែរទាំងឡាយប្រហែលជាដឹងហើយថា នៅក្នុងឆ្នាំ ២០០៤ គ្មានហាងទូរស័ព្ទនៅក្នុងផ្សារសូរិយាទេ។ ប៉ុន្តែមានសាខាក្រុមហ៊ុនទូរស័ព្ទហេឡូមួយ ដែលតាំងតូបរាងមូលពណ៌ខៀវលាយទឹកក្រូចនៅគែមៗ។ ហាងនេះមើលទៅយ៉ាងដូច្នោះឯង។

សិដ្ឋតែងតែទិញ រឺប្ដូរទូរស័ព្ទចល័តនៅទីនោះ។ នាងរមែងអង្គុយចុះ ហើយវែកសក់ពីមុខអាជីវករម្នាក់នោះ។

បុរសម្នាក់នោះឈ្មោះ តារា ដែលមានន័យថាផ្កាយ។ តារាដឹងទាំងអស់ពីពាណិជ្ជកម្មរវាងតម្លៃហៅចេញចូល ស៊ីមកាត និងទូរស័ព្ទចេញថ្មីៗដែលអាចចាក់វីដេអូបាន។ គាត់អាចបញ្ចូលចម្រៀងទូរស័ព្ទមួយណាក៏បាន ដែលនាងពេញចិត្ត។

និពន្ធដោយ៖ ជីអូហ្វ រីមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ *F*

ការជជែកគ្នាជាមួយតារាមិនបានបំពានលើច្បាប់របស់សិដ្ឋទេ។ គាត់មិនធាត់ ហើយក៏មិនជាស្គៀកពាក់ហ៊ឺហា ម្យ៉ាងអាយុច្រើនជាងយុវវ័យ ពោលគឺអាយុ ២៤ ឆ្នាំ មានគំនិតស្រគត់ស្រគំ។

នាថ្ងៃមួយ តារាក៏សើចក្អាកក្អាយ ហើយស្រដីថា៖

- ក្នុងនាមជាមិត្តភក្តិ ខ្ញុំសូមប្រាប់នាងទៅចុះ។ នាងមិនចាំបាច់ទិញទូរស័ព្ទថ្មីទៀតទេ។

សិដ្ឋជ្រួញច្រមុះ។

- ខ្ញុំមិនចង់បានអាមួយនេះទៀតទេ ព្រោះវាមានពណ៌ខៀវ។ ខ្ញុំចង់បានអាម៉ូតណាដែលមានលក្ខណៈជារបស់ស្រីបន្តិច ប៉ុន្តែមិនត្រូវក្បាច់ក្បូរច្រើនពេកទេ ហើយគួរតែមានគុណភាពសម្លេងល្អជាងហ្នឹង។

- យល់ព្រម ប៉ុន្តែនាងអាចសន្សំលុយទាំងនោះទុកទិញសម្លៀកបំពាក់ស្អាតៗបានណា៎។

កូនស្រីរបស់ប៉ុល ពតម្នាក់នេះបន្ទាបចង្ការរបស់នាង ធ្វើឲ្យកនាងវែង និងស្រស់សោភា។

- តើលោកចូលចិត្តសម្លៀកបំពាក់របស់ខ្ញុំដែររឺទេ?

- ម៉េចក៏មកសួរខ្ញុំទៅវិញ?

នាងញាក់ស្មា។

- ខ្ញុំមិនដឹងដែរ តែការចង់ដឹងពីរូបរាងខ្លួនឯងក៏ល្អម្យ៉ាងដែរ។

តារាងក់ក្បាលយល់ស្រប។

- នាងមើលទៅឡូយដែរតើ។ តើប្អូនស្រីនាងថាយ៉ាងម៉េចដែរ?

សិដ្ឋបង្ហាញទឹកមុខប្រាប់គាត់ថានាងគ្មានគ្រួសារទេ។

- អ៊ូ!- គាត់ឧទានឡើង ហើយក៏ប្រញាប់ផ្លាស់ប្តូរប្រធានបទ។ ពិតជាអស្ចារ្យណាស់។ ការលាក់កំបាំង និងការអាណិតអាសូរគឺជាដំណើរមួយយ៉ាងងាយស្រួល។

សិដ្ឋត្រលប់មកហាងនោះនៅថ្ងៃបន្ទាប់ ហើយត្អូញថា ទូរស័ព្ទពណ៌កូលាបនោះមានលក្ខណៈដូចស្រីពេកហើយ។ តារាអស់សំណើចយ៉ាងខ្លាំង រហូតទាល់តែភ្នែករលីងរលោង។ សិដ្ឋមករាងថ្ងៃបន្តិចហើយ ដូច្នេះតារាក៏សាកសួរទៅនាង។

- តើនាងឃ្លានទេ? ចង់ទៅញ៉ាំបាយថ្ងៃត្រង់ជាមួយខ្ញុំដែររឺ?

តើគាត់នឹងគិតថានាងជាស្រីចិត្តងាយរឺប្រសិនបើនាងឆ្លើយថាស? រឺក៏គាត់គិតថានាងលេងឬកប្រសិនបើនាងឆ្លើយទេ?

- ញ៉ាំឯណាក៏បានដែរឲ្យតែនៅក្នុងផ្សារសូរិយានេះ- នាងឆ្លើយតប។

នាងនៅមិនដាច់ស្រឡះរវាង ប៊ីប៊ីវើល ប៊ីហ្គើ និង ឡាក់គី សេវ៉ែន។ ហាងប៊ីប៊ីវើលធំ មូល ហើយនៅតែពីរជាន់ពីដោមប៉ុណ្ណោះ។ ឡាក់គី សេវ៉ែន នៅជាប់នឹងផ្សារទំនើបឡាក់គី ប៉ុន្តែហាងនេះ សេវាកម្មថ្លៃ គ្រាន់តែ ម៉ាកស៍វេល ហោស មួយកូនចានតូចថ្លៃ ២ ដុល្លារ ៤០ សេនទៅហើយ។

ពួកគេក៏សម្រេចចិត្តទៅ ប៊ីប៊ីវើល។ នៅទីនោះសំបូរទៅដោយពន្លឺ ហើយពួកគេអាចមើល ឃើញទីក្រុងទាំងមូលតាមបង្អួចកញ្ចក់ធំៗទាំងនោះ។ សិដ្ឋអង្គុយយ៉ាងស្ងាត់ស្ងៀម។

កូនស្រីប៉ុលពតម្នាក់នេះគ្មានអ្វីត្រូវនិយាយឡើយ លុះត្រាតែពេលនាងដើរទិញអីវ៉ាន់។

តែក៏ប្រហែលជានាងមានតែរឿងមួយគត់ដែលត្រូវនិយាយ ប៉ុន្តែនាងមិនត្រូវនិយាយអំពីរឿង នោះជាដាច់ខាត។

តារាជាអ្នកនិយាយរហូត។ គាត់បរិយាយតាំងពីកាលដែលគាត់ចរចាគ្នាជាមួយពួកអាជីវករ នៅជាន់ទីបីដើម្បីយកឌីសចម្លងដើមនៃហ្គេម ចោរលួចឡាន (Grand Theft Auto)។ គាត់ថែមទាំងលួច ប្រាប់ថាសិដ្ឋពីរបៀបទិញទំនិញដោយទទួលបានការបញ្ចុះតម្លៃទៀតផងនៅឯ ប៊ីអេស ហ្វេស្ទិន ដែល ជាហាងទំនើបភ្លឺចិញ្ចាចមួយនៅជាន់ខាងក្រោម។

ពេលនោះស្រាប់តែគាត់ឈប់ភ្លាម។

- នាងមិនចាំបាច់ខ្លាចខ្ញុំទេ។

គាត់និយាយដោយសំឡេងដូចមនុស្សចាស់ទុំ ប្រកបដោយសណ្ដានចិត្ត។

- ខ្ញុំមើលដឹងថា នាងគឺជាក្មេងស្រីដែលធំឡើងយ៉ាងសមសួនម្នាក់។ ខ្ញុំចូលចិត្តណាស់។

សិដ្ឋនៅតែមិនអាចរកនឹកពាក្យអ្វីនិយាយបាន។ នាងអាចត្រឹមតែងក់ក្បាលតាមប៉ុណ្ណោះ។ នាងចង់តែរត់ចេញទេ។

- តើនាងចង់ទៅហាង ខេ ហ្វ៊ុរ ទេ?

ខេ ហ្វ៊ុរ គឺជាហាងអេឡិចត្រូនិចដ៏ធំមួយ ស្ដុកទុកទៅដោយឧបករណ៍ម៉ាកល្បីៗដូចជា ហ៊ីតាឈី សូនី ប៉ាណាសូនិច ហ្វីលីព រឺក៏ ដេណុង។ ហាងនេះលក់របស់ថ្លៃៗណាស់ ស្ទើរតែគ្មាន នរណាចូលមកទិញឡើយ ហើយនេះក៏ជាមូលហេតុដែលសិដ្ឋចូលចិត្តហាងនេះដែរ។ មនុស្សមួយ ហ្វូងឈរនៅខាងក្រៅហាង ហើយសម្លឹងមើលតាមបង្អួចឯទូរទស្សន៍ដ៏ធំមួយចាក់បញ្ចាំងរឿង “សម័យទឹកកក”។ នៅលើអេក្រង់ សត្វតូចមួយកំពុងតែត្រូវផ្ទាំងទឹកកកដេញតាម។ វាពិតជាស្អាតខ្លាំង ណាស់!

ទើបតែដល់ពេលនេះទើបសិដ្ឋរកនឹកឃើញពាក្យនិយាយ។

- ប្រសិនបើខ្ញុំមានតែអាហ្នឹងមួយ អញ្ចឹងមិនចាំបាច់ចេញពីផ្ទះទៀតទេ។

និពន្ធដោយ៖ ជីអូហ្វ រ៉ៃមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ *F*

តារា មៀងមើលនាង ហើយក៏សើច។

នៅថ្ងៃបន្ទាប់មកទៀត សិដ្ឋក៏មកប្រាប់គាត់ថា ទូរស័ព្ទដៃដែលនាងមានទាំងប៉ុន្មានធំពេកហើយ។ តើគាត់មានអាប្រភេទណាដែលនាងអាចពាក់ជុំវិញករបស់នាងដូចជាគ្រឿងអលង្ការទេ?

លើកនេះពួកគេទៅ ឡាក់គី សេវ៉ែន ប៊ីហ្គ៊ី ម្តង ហើយអង្គុយចុះនៅទល់មុខតូប វ៉េវឡូន។ ពួកគេគយគន់ក្មេងប្រុសៗកំពុងតែត្រូវអ្នកជំនាញផ្នែកកែសម្ផស្សធម្មជាតិរបស់ វ៉េវឡូន លាបសក់ឲ្យ។

តារាក៏រៀបរាប់ប្រាប់នាងបន្ថែមទៀតអំពីខ្លួនគាត់។ ឪពុករបស់គាត់បានស្លាប់នៅក្នុងសង្គ្រាម។ គ្រួសាររបស់គាត់ឥឡូវរស់នៅជនបទ។ មកដល់ត្រឹមនេះ ស្រាប់តែកូកា កូឡារបស់សិដ្ឋប្រែជាមានរសជាតិដូចថ្នាំគ្រុនចាញ់ទៅវិញ។

- ប៉ុន្តែ...លោកមិនចង់រស់នៅឯជនបទទេ មិនថាអញ្ចឹង- នាងស្រដី។

- ទេ។ ខ្ញុំត្រូវមកភ្នំពេញដើម្បីរកប្រាក់។ ប៉ុន្តែសាច់ញាតិរបស់ខ្ញុំសុទ្ធតែជាអ្នកស្រែល្អៗ។ ពួកគាត់មានសុជីវធម៌ណាស់។- គាត់ក៏សើច បែបអៀនខ្មាស។

*ពួកគេច្បាស់ជាមានមាន់ទា ហើយនិងបងប្អូនជីដូនមួយម្នាក់ដែលឡើងដើមដូង។ នៅទីនោះសុទ្ធតែព្រៃឈើ ប៉ុន្តែគ្មានហាងនោះឡើយ។ ធូលីដីនៅទីនោះច្បាស់ជាធុំក្លិនអាក្រក់ជាមិនខាន។*

សិដ្ឋធឹកភេសជ្ជៈរបស់នាងលែងចូលទៀតហើយ។ នាងដកដង្ហើមធំ ហើយក៏និយាយភ្លាម៖

- ឲ្យខ្ញុំសុំទោស។ ខ្ញុំក៏មិនចង់ដែរ ប៉ុន្តែខ្ញុំត្រូវទៅហើយ។- នាងក៏រំកិលខ្លួនចេញពីកៅអីរបស់នាងយឺតៗដូចរង្វូអញ្ចឹង។

ពេលដើរត្រលប់ទៅវិញកាត់តូបលក់គ្រឿងអលង្ការដោយគ្មានអ្វីធ្វើ នាងក៏ចាប់អារម្មណ៍ថា តារាច្បាស់ជាយល់ថានាងមិនចូលចិត្តគាត់ហើយ។

ហើយរឿងនោះធ្វើឲ្យភ្នែកនាងផ្នែកខាងក្រោមឈឺតែម្តង។

នាងត្រលប់ទៅវិញនៅថ្ងៃបន្ទាប់ ព្រមទាំងលែងធ្វើពុតជាទិញទូរស័ព្ទដៃទៀតហើយ។ នាងប្រាប់តារាថា នាងចាកចេញទាំងតក់ក្រហល់នៅថ្ងៃនោះក៏ព្រោះតែនាងនឹកឃើញថាត្រូវទៅធ្វើសក់។

គាត់ក៏តបវិញថា នាងដូចជាយកចិត្តទុកដាក់ចំពោះសក់របស់នាងពេកហើយ។ បន្ទាប់មកគាត់ក៏ណាត់នាងទៅមើលកុននៅយប់នោះ។

សិដ្ឋចំណាយពេលពេញមួយថ្ងៃដើរទិញអីវ៉ាន់នៅក្នុងហាង ខេ ហ៊័រ។

ពួកគេជួបគ្នានៅម៉ោងប្រាំមួយ។ តារាបានគិតគូរយ៉ាងម៉ត់ចត់ ដោយគាត់មិនបានជ្រើសរើសរឿងកុនរន្ធត់ឡើយ។ គាត់និយាយថាគាត់ចង់មើលរឿង "ក្មេងស្រីក្របីលាក់ខ្លួន" ដែលតំណាលពីរឿង

ក្មេងស្រីជនបទម្នាក់រស់នៅឯស្រែ។ សិដ្ឋនិយាយដោយទឹកចិត្តសោមនស្សថា នាងចង់មើលរឿងរន្ធត់ជាង។

រោងកុននៅជាន់លើបង្អស់បើកទ្វារចេញទៅលើដំបូលផ្សារសូរិយាចំតែម្ដង។ ក្រដាសបិតតាមជញ្ជាំងត្រូវដាច់ដោចខ្ទេចខ្ទីរហូតដល់បង្កាន់ដៃពណ៌បៃតង។ ហេតុអ្វីបានជាគេចូលចិត្តបំផ្លាញរបស់ដែលថ្មី និងស្អាតបែបនេះ? សិដ្ឋកាន់ដៃតារា ហើយដឹងថាពួកគេឥឡូវក្លាយជាសង្សារនឹងគ្នាហើយ។

- ចុងបញ្ចប់- គាត់ពោល។

- ចុងបញ្ចប់អី?

- នាងបានធ្វើអ្វីមួយហើយ។

ពួកគេផ្អែកខ្លួននឹងបង្កាន់ដៃ ហើយសម្លឹងពីលើផ្ទះរបស់ប្រជាជន។ ទៅទិសខាងលិចជិតទន្លេគឺជាអគារមួយដែលមានលានដំបូលយ៉ាងទូលាយ។ ពួកស្រីៗប្រជុំគ្នានៅទីនោះដើម្បីនិយាយដើមគេ។ ក្មេងៗកំពុងតែលេងចោលឈ្លូង។ នៅពីចម្ងាយ សិដ្ឋពិតជាស្លុងអារម្មណ៍ណាស់។

- ខ្ញុំពិតជាចូលចិត្តមើលក្មេងៗណាស់។

រឿងកុននោះគឺជារឿងថៃនិយាយពីស្ត្រីម្នាក់ដែលមុខប្រែជាពណ៌ខៀវ និងមានស្នាមអុជៗថែមទាំងចាប់ស៊ីពួកប្រុសៗ។ ស្ត្រីពណ៌ខៀវនោះពិតជាគួរឲ្យខ្ពើមមែន តែមិនគួរឲ្យខ្លាចជាងសម្លេងនៅក្នុងរឿងនោះទេ។ តួអង្គនៅក្នុងរឿងនោះស្ដាប់មើលទៅដូចជាត្រូវមន្តអាគមអញ្ចឹង។ មើលទៅហាក់ដូចជាពួកថៃត្រូវព្រលឹងខ្មោចខ្មែរទៅសណ្ឋិត។

ល្ពឹកណាសិដ្ឋភិតភ័យ នាងតែងតែសើច។

ដូច្នេះនាងក៏អង្គុយសើចដោយតក់ស្លុត។ តារាបែរជាគិតថា នាងកំពុងតែសើចចំអកថារឿងនេះអន់ ហើយយល់ថាគួរឲ្យអស់សំណើច។ គាត់ក៏ចាប់ផ្ដើមសើចតាមដែរ។ សិដ្ឋគិតថាគាត់ក៏ប្រហែលជាខ្លាចដូចនាងដែរហើយ។ នៅក្នុងទីងងឹតនោះ ពួកគេទាំងពីរក៏ចាប់ដៃគ្នា។

ក្រោយមកនៅខាងក្រៅ អាកាសធាតុនៅតែស្អាប់ស្អុះទោះជាយប់ហើយក៏ដោយ ហើយផ្លូវលេខ ១៤២ មានធុំក្លិនលូទឹកស្អុយ។ សិដ្ឋឈរលើចុងជើងដើម្បីចៀសពីផ្លូវរអិល និងឆ្អឹងត្រីបោះចោល។

តារាស្នើថា៖

- ចាំខ្ញុំជូននាងទៅផ្ទះ។

- អ្នកបើកឡានរបស់ខ្ញុំអាចជូនពួកយើងទៅបានហើយ- សិដ្ឋតប ដោយរលាស់ទូរស័ព្ទម៉ាក Kermit-the-Frog របស់នាង។

ឡានម៉ាសែដែស ប៊ិន ពណ៌ខ្មៅរបស់នាងអែបសំចត ព្រមទាំងកិនដបផ្លាស្ទិចចាស់ៗជិតមាត់លូពួសូរប្រែសៗ។ កៅអីអង្គុយសុទ្ធតែគ្របដណ្តប់ដោយស្បែកសត្វពណ៌ដាំដែង ហើយអ្នកបើកឡានប្រដាប់អាវុធទៀត។

តារាចំហមាត់ឆ្លុង។

- តើ...តើឪពុកនាងជានរណា?

- គាត់ស្លាប់ហើយ។

តារាគ្រវីក្បាល។

- តើគាត់ជានរណា?

ជាធម្មតាសិដ្ឋតែងប្រើឈ្មោះតាមខ្សែស្រឡាយម្តាយនាង ប៉ុន្តែនោះមិនអាចឆ្លើយតបនឹងសំណួរនេះទេ។ ដោយភ័ន្តភាំង នាងក៏ចាប់ផ្តើមរកនឹកមើលនរណាម្នាក់ដែលអាចជាឪពុករបស់នាង។ នាងមិនស្គាល់នរណាម្នាក់មានអាយុប្រហាក់ប្រហែលហ្នឹងសោះ។ នាងនៅចាំរឿងខ្លះពីអ្នកនយោបាយម្នាក់ដែលបានស្លាប់។ ឈ្មោះរបស់គាត់ក៏លេចឡើងនៅក្នុងខួរក្បាលរបស់នាង ហើយនាងក៏ប្រញាប់ឆ្លើយយ៉ាងស្លន់ស្លោរ។

- ឪពុករបស់ខ្ញុំឈ្មោះ កុល វីរៈបុត្រ។

តើនាងហៅឈ្មោះត្រូវទេ?

- សូមកុំប្រាប់នរណាអី។

តារាយកដៃបិទភ្នែករបស់ខ្លួន។ - ពួកយើង...គ្រួសារខ្ញុំ ឪពុកខ្ញុំ...ពួកយើងសុទ្ធតែប្រយុទ្ធដើម្បី KPLA ។

សិដ្ឋទប់ចិត្តខ្លួនឯងមិនឲ្យសួរថាតើ KPLA នោះគឺជាអ្វី។

កុល វីរៈបុត្របានដឹកនាំបក្សពួកមួយក្រុមកាលពីសម័យសង្គ្រាមស៊ីវិល។ បក្សនេះប្រយុទ្ធប្រឆាំងនឹងខ្មែរក្រហម ពួកវៀតណាម ព្រះមហាក្សត្រ និងអំពើពុករលួយ ព្រមទាំងចង់បានមាគ៌ាថ្មីមួយសម្រាប់ប្រទេសកម្ពុជា។ កុល វីរៈបុត្រគឺជាអ្នកដឹកនាំកម្ពុជាមួយរូបដែលមិនដែលនិយាយពាក្យបោកប្រាស់ រឺទទួលសំណូកឡើយ។

ចូរចាំថានេះគឺជារឿងមិនពិតឡើយ។

តារាចាប់ផ្តើមថយខ្លួនចេញឆ្ងាយពីឡាននោះ។

- ខ្ញុំមិនគិតថាពួកយើងគួរតែធ្វើអញ្ចឹងនោះទេ។ និយាយឲ្យត្រង់ទៅ ខ្ញុំគ្រាន់តែជាភូមិករម្នាក់ប៉ុណ្ណោះ។

- នោះមិនមែនជាបញ្ហាទេ។

គាត់បិទភ្នែក។ - ខ្ញុំមិនចង់ធ្វើឲ្យអាប់អោនកិត្តិយសដល់កូនស្រីរបស់លោក កុល វីរៈបុត្រ នោះទេ។

អូ! ព្រះអើយ! នាងចេះតែរកនឹកឈ្មោះយកមកនិយាយឲ្យរួចខ្លួនប៉ុណ្ណឹង មិននឹកស្មានថាបង្កឲ្យមានបញ្ហាដល់ថ្នាក់ហ្នឹងសោះ។

- សូមអង្វរ!- នាងស្រដី។

តារាដកដង្ហើមធំ។

- យល់ព្រម។ ខ្ញុំបាននិយាយហើយថា ខ្ញុំនឹងមើលនាងទៅដល់ផ្ទះដោយសុវត្ថិភាព។ ខ្ញុំនឹងធ្វើតាមពាក្យសន្យា។-

នៅក្នុងឡាន ម៉ាសែដែស គាត់ក៏ដាក់ខ្លួនអង្គុយប៉ូកទៅលើកម្រាលស្បែកសត្វពណ៌ដាំដែង។

នៅពេលដែលពួកគេទៅដល់ តារាក៏ផ្អៀងកមើលទៅផ្ទះសិដ្ឋ។

- តើនាងនៅជាន់ទីប៉ុន្មាន?

- គ្រប់ជាន់។

មុខរបស់តារាប្រែជាស្លេកស្លាំង។

- អ្នកបើកឡានរបស់ខ្ញុំនឹងជូនលោកទៅវិញ- នាងនិយាយទៅកាន់តារា។ ខណៈពេលដែលឡានថយចេញទៅ នាងឈរនៅខាងក្រៅរបង បក់ដៃលាគ្នាយ៉ាងស្រងូតស្រងាត់។

បន្ទាប់មក សិដ្ឋក៏អន្ទះសាភ្លាម។ តើកុល វីរៈបុត្រជានរណា? នាងក៏បើកអន្តរបណ្ដាញ ហើយស្វែងរកតាម ហ្គូហ្គល (Google) ។ នាងត្រូវអានពីសង្គ្រាម ដែលធ្វើឲ្យនាងព្រឺសម្បុរខ្លាកៗ។ បក្សពួកក្រុមខុសៗគ្នាទាំងអស់នោះរសាត់អណ្តែតនៅក្នុងខួរក្បាលរបស់នាង៖ ANS, NADK, KPR និង KPNLF។ ឈ្មោះទាំងអស់នេះហាក់ដូចជាដង្ហោយហៅមករកនាង ដោយសម្លេងពីអតីតកាលអញ្ចឹង។

មិនយូរប៉ុន្មាននាងក៏អស់ភាពអំណត់ ទ្រាំលែងបានតទៅទៀត។ នាងក៏បោះពុម្ពរូបរបស់ វីរៈបុត្រ ហើយសម្រេចចិត្តថាយកទៅឲ្យគេដាក់ស៊ុម។ ការពារខ្លាចក្រែងតារាមកលេង។

កុល វីរៈបុត្រមានមុខមូល និងស្នាមញញឹមពោរពេញដោយក្ដីស្រឡាញ់របស់ឪពុក។ ភ្នែករបស់គាត់ទាំងពីរហាក់ដូចជាដៀងមើលទៅលើសំដៅច្រមុះគាត់ មើលទៅសំបូរទៅដោយការយល់ដឹងជ្រៅជ្រះ។ គាត់ត្រូវបានគេធ្វើឃាតដោយផ្ទុះគ្រាប់បែកស្លាប់ក្នុងឡាន។

ពេញមួយយប់នោះ សិដ្ឋលើសម្លេងខ្សឹបខ្សៀវរហូត។

នៅព្រឹកឡើង មានរូបភាពនរណាម្នាក់ទៀតនៅលើផ្ទៃម៉ាស៊ីនបោះពុម្ពរបស់នាង។

រូបស្ត្រីមុខវែង ធ្មេញទន្សាយសខ្មៅម្នាក់បានសម្លក់មកនាង។ សិដ្ឋកត់សម្គាល់ពីកំហុសក្នុងការតុបតែងខ្លួនរបស់ជនរងគ្រោះនេះ។ សក់របស់ស្ត្រីនេះរញ៉េរញ៉ៃ និងកណ្តាញ់គ្រប់កន្លែង។ បើសិនជានាងវិញ ច្បាស់ជាទៅឲ្យគេអ៊ុតឲ្យត្រង់ ហើយហាយឡាយឲ្យស្អាតហើយ។ ភ្នែករបស់ស្ត្រីនោះសម្លឹងមើលមកនាងឡើងចង់ធ្លុះ។

- ប៉ះពាល់ខ្ញុំមិនបានទេ- សិដ្ឋពោល។ នាងទុករូបថតនោះចោលនៅលើផ្ទៃ រួចនាងទៅជួបតារាភ្លាមតែម្តង ដោយគ្មានបានស្រស់ស្រូបអាហារពេលព្រឹកទេ។

ភ្នែករបស់គាត់ទាំងពីរមានរង្វង់ខ្មៅៗជុំវិញ ហើយខោអាវ "ហេឡូ" ពណ៌ខៀវរបស់គាត់អ៊ុតមិនបានស្អាតបាតទេ។

- ទិញហាងហ៊ឹងទាំងមូលតែម្តងទៅ- តារាស្រដី មើលទៅដូចជាអារម្មណ៍មិននឹងនរ។ - ពួកអាជីវករនៅហាង យេហ៊័រ ទើបតែប្រាប់ខ្ញុំទេមាននារីម្នាក់ស្លៀកខោ ខូវប៊យ ពណ៌ខៀវដើរចូលទៅកាលពីម្សិលមិញ ហើយកុម្ម៉ង់ទូរទស្សន៍ដាក់ផ្ទះពីរគ្រឿងធំៗ។ នារីនោះនិយាយថា មួយដាក់នៅសាឡុង ហើយមួយទៀតដាក់នៅលានដំបូល។ នាងបង់ថ្លៃទូរទស្សន៍ទាំងពីរនោះដាច់តែម្តង ហើយបញ្ជាឲ្យគេដឹកយកទៅដាក់ផ្ទះនៅខាងចុងផ្លូវមុនីវង្ស។

សិដ្ឋដកដង្ហើមធំ។

- ខ្ញុំបញ្ជូនមួយមកវិញហើយ។- នាងសង្ឃឹមថាចម្លើយនេះស្តាប់ទៅមិនវាយឫកនោះទេ។ - វាមើលទៅដូចជាសំបូរជាតិដែកណាស់ មិនស៊ីគ្នានឹងវាំងននខ្ញុំទេ។

មានការស្ងប់ស្ងាត់មួយសន្ទុះ។

- នារីម្នាក់នោះក៏បានទិញផ្លែយន្ត អាយដូ មួយដែរ ក្នុងតម្លៃ មួយពាន់ប្រាំរយ ដុល្លារ។

បើតារាមិនដឹងអំពីផ្លែនោះ ប្រហែលជាល្អជាង។ វាគ្រាន់តែជារបស់លេងឡប់ៗតែប៉ុណ្ណោះ។ នាងមិនគិតថាវាថ្លៃដល់ម្លឹងនោះទេ។

- ពួកគេមិនគួរប្រាប់អ្នកដទៃអំពីរឿងរបស់អតិថិជនរបស់ពួកគេទេ បើមិនអញ្ចឹងទេមិនយូរមិនឆាប់ច្បាស់ជាគ្មាននរណាមកទិញទៀតជាមិនខាន។

តារាកំពុងតែសម្លឹងមើលមកនេះហាក់ដូចជាគិតថា៖ *នេះមិនមែនគ្រាន់តែជាស្រីស្អាតបាតម្នាក់ដែលគួរឲ្យស្រឡាញ់ប៉ុននោះទេ។*

- ខ្ញុំសប្បាយណាស់កាលពីយប់មិញ- សិដ្ឋនិយាយដោយសម្លេងឆ្មារៗដូចពពកសាត់។

-ខ្ញុំក៏អញ្ចឹងដែរ។

- យើងមិនចាំបាច់ប្រាប់គេអំពីគ្រួសាររបស់ខ្ញុំទេ។ មែនទេ?- សិដ្ឋពិតជាខ្លាចបាត់បង់រូបគាត់ណាស់។

- មិនបាច់ទេ។ ប៉ុន្តែ សិដ្ឋ រឿងនេះមិនអាចទៅរួចទេ។ គ្រួសាររបស់នាង ហើយនិងគ្រួសាររបស់ខ្ញុំ ពួកយើងមិនសក្តិសមនឹងគ្នាឡើយ។

-វាមិនខុសគ្នាទេ។

- នាងបានកុហកខ្ញុំ។ គ្រួសាររបស់នាងមិនស្លាប់ទាំងអស់ទេ។ នាងនៅមានឳពុកមាល្បីៗជាច្រើនរូបទៀត។

នាងពិតជាមានមែន...គឺលោកពូ អៀង សារី លោកពូ ខៀវ សំផន លោកពូ តា ម៉ុក។ បក្សពួក ប៉ុល ពតទាំងអស់សុទ្ធតែជាលោកពូរបស់នាង។

-ខ្ញុំមិនសូវស្គាល់ពួកគេច្រើនទេ។-នាងតប។ នេះក៏ជាការពិតដែរ។

តើនាងនឹងធ្វើអ្វីបានប្រសិនបើនាងមិនអាចទិញទំនិញនៅក្នុងផ្សារសូរិយាទៀតបាន? តើនាងនឹងធ្វើយ៉ាងម៉េចទៅប្រសិនជាគ្មានតារានោះ?

នាងក៏សុំអង្វរ។

- ខ្ញុំមិនមែនជាមនុស្សរឹងមាំអ្វីទេ។ ជួនកាលខ្ញុំគិតថាខ្ញុំមិនមែនជាមនុស្សផង។ ខ្ញុំគ្រាន់តែជាលំហាទទេស្អាតប៉ុណ្ណោះ។

តារាស្រាប់តែសំដែងអាការកាច។

-នាងគ្រាន់តែជាបណ្ណាគណទានប៉ុណ្ណោះ។

បន្ទាប់មកគាត់ក៏ឈ្ងោកមុខចុះ។

- ឲ្យខ្ញុំសុំទោស។ ខ្ញុំមិនគួរនិយាយដូច្នោះទេ។ អាយុប៉ុណ្ណឹង នាងនៅក្មេងណាស់ ហើយខ្ញុំជាមនុស្សចាស់ជាងនាង គួរតែចេះអធ្យាស្រ័យឲ្យនាងឲ្យបានច្រើន។

សិដ្ឋប្រែជាអស់សង្ឃឹម។

-លុយរបស់ខ្ញុំទាំងអស់នោះច្បាស់ជាល្អណាស់ហើយ។

-ខ្ញុំមិនមែនសម្រាប់លក់ទេ។

គាត់ធ្វើការនៅក្នុងហាងមួយ ហើយត្រូវផ្ញើលុយទៅកាន់គ្រួសារដែលគ្មានឳពុកមួយទៀត។ អញ្ចឹងហើយនៅថា គាត់មិនមែនសម្រាប់លក់ទៀត!

សិដ្ឋមានបេះដូងចង្អៀតចង្អល់ ប៉ុន្តែក៏ចេះគិតគូរដែរ។ នាងដឹងថា នាងត្រូវតែធ្វើអ្វីមួយដែលសមគួរ ដូចជាការរើសផ្កាដូច្នោះដែរ បើមិនអញ្ចឹងទេ ផ្កានោះច្បាស់ជាត្រូវស្រពោនងាប់ហើយ។

- តោះ...ទៅមើលកុនទេ?

ទោះយ៉ាងណា នាងមានសម្រស់ស្រស់ស្អាត និងធំធាត់ពីត្រកូលគ្រួសារល្អ ហើយនាងដឹងច្បាស់ថាភ្នែកទាំងគូរបស់នាងមូលៗ ហើយធំទៀត។ បេះដូងដ៏តូចរបស់នាងមួយនេះកំពុងតែឈឺចាប់ហើយ។

លើកនេះពួកគេមើលរឿង ទុំទាវ ដែលជារឿងថតឡើងវិញ ខុសពីរឿងបុរាណកាលពីជំនាន់ហុកសិប។ ប្រសិនបើរឿងណាមិនតែងទាក់ទងនឹងសុបិនអាក្រក់អំពីខ្មោចទេ អញ្ចឹងច្បាស់ជានិយាយពីអតីតកាលហើយ។ សិដ្ឋសញ្ជឹងគិតថា *តើអង្កាល់ទៅទើបគេថតរឿងដែលនិយាយពីអនាគតរបស់កម្ពុជា?* រឿងទុំទាវ ដកស្រង់ចេញពីរឿងព្រេងបុរាណមួយអំពីសង្ឃក្មេងម្នាក់ ដែលលង់ស្នេហ៍កូនស្រីអ្នកមានម្នាក់ ប៉ុន្តែត្រូវម្ដាយខាងស្រីរារាំង។ នៅចុងបញ្ចប់ ពួកគេទាំងពីរនាក់ក៏ធ្វើអត្តឃាត ដោយបានពាំនាំមកនូវបណ្ដាសាមួយមកលើភូមិរបស់ពួកគេ។ សិដ្ឋអង្គុយមើលរឿងនោះឡើងស្ងឹងស្ងាធិ។ *ខ្ញុំច្បាស់ជាមិនក្លាយជាតួឯកស្រីដែលត្រូវស្លាប់នៅក្នុងរឿងស្នេហាជាដាច់ខាត។*

តារាបានសំណូមពរជូននាងទៅផ្ទះម្ដងទៀត ហើយនៅពេលនោះឯង ដែលសិដ្ឋដឹងថាគាត់ជិះម៉ូតូ ហុងដាឌ្រីម។ គាត់បានបង្ហាញប្រាប់នាងយ៉ាងមោទនៈពីម៉ូតូដ៏ភ្លឺចិញ្ចាចដែលបុរសសម័យថ្មីជិះ។ សិដ្ឋមានអារម្មណ៍ថាមកដល់ទីទ័លច្រក។ នាងបានស្ដីថាចង់ទិញគាត់ម្ដងហើយ។ ប្រសិនជានាងបង្អួតពីឡានរបស់នាងទៀត អាចនឹងធ្វើឲ្យគាត់បោរមុខមិនខាន។

ដូច្នេះនាងក៏ដាច់ចិត្តបំពានលើច្បាប់ទីប្រាំពីរ។

តារាលាក់កាបូបរបស់នាងនៅក្នុងកែបខាងក្រោយ ហើយពួកគេក៏ជិះតាមមហាវិថីព្រះមុនីវង្សនាពេលយប់។ តាមផ្លូវពួកគេឃើញ ជនអនាថា ស្រីពេស្យាចារ ហើយនិងចុងភៅដែលដើរត្រេតត្រូតទៅផ្ទះបន្ទាប់ពីចេញពីធ្វើការ។ ពេលនោះជាពេលបំណាច់ឆ្នាំទេ ប៉ុន្តែស្រាប់តែមានភ្លៀងធ្លាក់។

សិដ្ឋចូលចិត្តសភាពបែបនេះណាស់។ ខ្យល់ត្រជាក់បក់ផាយផាត់ប៉ះមុខរបស់នាង និងតំណក់ទឹកភ្លៀងនៅរណេងរណោងជាប់នឹងរោមភ្នែករបស់នាង។

នាងនៅចាំកាលពីអាយុប្រាំឆ្នាំ កាលពីនាងរាំលេងនៅក្នុងព្រៃក្រោមភ្លៀងមូសុង។ នាងយកដៃអោបចង្កេះរបស់តារាដើម្បីទប់ខ្លួន ហើយក៏យកថ្ពាល់របស់នាងកើយលើខ្នងរបស់គាត់។ នាងសើចកក្អឹកដោយភ័យ មិនមែនដោយសារភ្លៀងទេ គឺដោយសារតែអារម្មណ៍របស់នាង។

និពន្ធដោយ៖ ជីអូហ្វ រីមែន (Geoff Ryman)

ប្រែសម្រួលដោយ៖ *F*

គាត់ឱបនាងទៅដល់ផ្ទះ។ នៅខាងក្នុងផ្ទះនាង អ្វីៗទាំងអស់សុទ្ធតែងងឹតលើកលែងតែពន្លឺភ្លិបភ្លែតពណ៌បៃតងដែលចេញពីម៉ាស៊ីនបោះពុម្ពរបស់នាងប៉ុណ្ណោះ។ នៅលើជញ្ជាំងមានរូបថតថ្មីពីរទៀត។ រូបមួយគឺជាក្មេងប្រុសតូចមួយ កំពុងតែកាន់សញ្ញាប័ត្របញ្ចប់ការសិក្សានៅសាលា។ រូបមួយទៀតគឺជាចាស់ព្រឹទ្ធាចារ្យដ៏រឹងប៉ឹងម្នាក់ ដែលមានស្នាមសាច់ជុំតាមខាងៗនៃស្នាមញញឹមដ៏ជូរចត់បែបចំអករបស់គាត់។ ពួកគេសម្លឹងមើលចំៗមកនាងតែម្តង។

*ពួកគេដឹងថាខ្ញុំជានរណា។*

ខណៈពេលដែលនាងឡើងជណ្តើរទៅកាន់បន្ទប់គេងរបស់នាង នាងស្រាប់តែឮនរណាម្នាក់កំពុងតែយំខ្សឹកខ្សួល តែនៅឆ្ងាយ ហាក់ដូចជាចេញមកពីផ្ទះជិតនោះ។ នាងស្ទាបជញ្ជាំងនៅជាប់នឹងកាំជណ្តើរនោះ ឃើញថាជញ្ជាំងនោះរង្គើតិចៗ ស្របតាមចង្វាក់នៃការយំនោះដែរ។

នៅក្នុងបន្ទប់គេងរបស់នាង នាងយកម៉ាស៊ីនអាយផតមួយចេញពីក្នុងចំណោមអាយផតជាច្រើនរបស់នាងដែលដាក់ព្យួរជាខ្សែ ហើយចាក់ស្តាប់បទចម្រៀង System of a Down ព្រមទាំងបើកសំឡេងអស់ៗតែម្តង។ ទាល់តែធ្វើបែបនេះទើបនាងដេកលក់។ សំឡេងនៃហ្គីតារនៅក្នុងចម្រៀងនេះហាក់ដូចជាខួរឡើងចេញពីបេះដូងរបស់នាងដូច្នោះដែរ។

នាងត្រូវបានដាស់ឲ្យភ្ញាក់ឡើងនៅពេលព្រឹកដោយសំឡេងកណ្តឹងរោទិ៍នៅជាន់ក្រោម។ នាងឮសម្លេងអ្នកថែរក្សាផ្ទះឈ្មោះ ចូរ៉ានី ស្រែកហៅ ហើយបើកទ្វារឡើង។ សិដ្ឋស្ទាក់ស្ទើរមិនដឹងជាត្រូវស្លៀកពាក់អាវ និងខោខូវប៊យមួយណា។ នៅពេលដែលនាងទៅដល់ជាន់ក្រោម នាងឃើញអ្នកបើកឡាន និងអ្នកថែរក្សាផ្ទះកំពុងតែនិយាយគ្នាលេងជាមួយតារាបណ្ឌិត ចាក់ទឹកតែជូនតារាបណ្ឌិត។

តារាហាក់ដូចជាបានបណ្តេញពួកខ្មោចឲ្យចេញឆ្ងាយប្រៀបបាននឹងរស្មីព្រះអាទិត្យកំចាត់ស្បែអន្ធការដូច្នោះដែរ។

- សួស្តី- គាត់ស្រដី។ - ថ្ងៃនេះជាថ្ងៃឈប់សម្រាក។ ខ្ញុំគិតថាចង់បបួលនាងជិះម៉ូតូដើរលេងទៅជនបទ។

ប៉ុន្តែមិនបាច់ទៅជនបទទេ។ តើពួកយើងមិនអាចទៅលេងនៅសូរិយាទេរឺ? តារាបដិសេធហើយថា មានកន្លែងដទៃៗទៀតជាច្រើនដែលត្រូវមើលនៅក្នុងទីក្រុងភ្នំពេញ។

គាត់ឱបនាង បត់បែនចុះឡើងតាមផ្លូវលំតូចៗ។ តើហេតុដូចម្តេចបានជាទីក្រុងនេះក្រីក្រយ៉ាងនេះ? យ៉ាងម៉េចបានជាកខ្វក់ម្ល៉េះ?

ពួកគេនាំគ្នាទៅហាងលក់ស៊ីឌីទំនើបទើបបើកថ្មីមួយ ដែលជារបស់ម្ចាស់ផលិតកម្មចម្រៀង។ តារាដឹងគ្រប់សព្វពីបទចម្រៀងពីរោះៗថ្មីៗ ភាគច្រើនច្រៀងដោយពួកខ្មែរកាត់អាមេរិក ដែលត្រលប់មកពីឡុងប៊ិច និងខុមតុន៖ ស្ពី, ភ្នំពេញបេដបយស៍, កូនខ្មែរ ។

សិដ្ឋទិញម្ភៃស៊ីឌី។

ពួកគេទៅលេងសារៈមន្ទីរជាតិ ហើយបានឃើញព្រះកេសរបស់ព្រះបាទជ័យវរ្ម័នទីប្រាំពីរ ដែលដូចគ្នានឹងព្រះកេសព្រះពុទ្ធ។ ដោយគ្មានគិតគូរច្រើន តារាក៏លុតជង្គង់ចុះ ហើយលើកដៃប្រណម្យបួងសួង។ ពួកគេញ៉ាំអាហារពេលល្ងាចនៅក្នុងហាងបារាំងមួយ អមដោយពន្លឺភ្លើងទៀន និងស្រាទំពាំងបាយជូរ ដូចជានៅក្នុងវីដេអូខារ៉ាអូខេអញ្ចឹង៖ ប្រុសម្នាក់ ស្រីម្នាក់ជាគូសង្សារ ដើរលេងជាមួយគ្នា។ ពួកគេទៅទស្សនាការសំដែងនៅរោងមហោស្រព សុវណ្ណភូមិ ហើយពួកគេឃើញរបាំមួយយ៉ាងអស្ចារ្យ ដែលយកលំនាំតាមបទចម្រៀងជំនាន់ឆ្នាំសែសិបក្នុងរឿងបារាំងបុរាណមួយ ដោយបញ្ចូលទំនុកភ្លេងប្រពៃណីរបស់ខ្មែរ។

សិដ្ឋត្រលប់ទៅផ្ទះវិញ ក្នុងបេះដូងរបស់នាងច្រៀងរងំៗ៖ *តារា តារា តារា* ។

នៅក្នុងបន្ទប់គេងរបស់នាង ទូរស័ព្ទដៃមួយគ្រឿងចាប់ផ្តើមរោទិ៍មិនឈប់។ នៅលើអេក្រង់ថា *Call 1* ប៉ុន្តែគ្មានឈ្មោះ រឺលេខទូរស័ព្ទឡើយ ដូច្នេះអ្នកដែលទូរស័ព្ទមកនោះមិនស្ថិតនៅក្នុងបញ្ជីទំនាក់ទំនងរបស់សិដ្ឋទេ។

នាងក៏បិទទូរស័ព្ទចោល។ វានៅតែរោទិ៍ដដែល។ លើកនេះ ទើបនាងដឹងថាជានរណា។

នាងដាក់ទូរស័ព្ទនោះក្រោមខ្នើយ ក្នុងបន្ទប់ដេកទំនេរមួយ ហើយដាក់ខ្នើយមួយជាន់ទៀតពីលើ បន្ទាប់មកបិទទ្វារចាក់សោរជិត។

ស្រាប់តែ ទូរស័ព្ទដៃរបស់នាងទាំងសែសិបពីរចាប់ផ្តើមរោទិ៍ព្រមៗគ្នា។ ពួកវារោទិ៍តាំងពីនៅក្នុងទូខោអាវ រឺក៏ក្នុងបន្ទប់ទឹក ដែលនាងច្រលំទុកចោល ហើយភ្លេចយកចេញមកវិញ។ ទូរស័ព្ទទាំងអស់នោះរោទិ៍តាំងពីលើលានដំបូល ទាំងនៅក្នុងស្បែកជើងដាក់ក្រោមគ្រែរបស់នាង។

- ខ្ញុំជាស្រីរឹងរូសណាស់!- នាងស្រែកដាក់ព្រលឹងទាំងអស់នោះ។ - អ្នកមិនអាចបន្លាចខ្ញុំបានទេ។

នាងបើកអាយផតរបស់នាង ហើយក៏ដេកលក់ទៅ។

ឲ្យតែព្រះអាទិត្យរះកាលណា នាងក៏ទៅដាស់អ្នកបើកឡានរបស់នាងភ្លាម ដែលកំពុងតែដេកលង់លក់ក្នុងអង្រឹង។

- ឆាប់ឡើង ពួកយើងត្រូវទៅផ្សារសូរិយា- នាងបន្លឺឡើង។

អ្នកបើកឡាននោះងើយមើលទាំងមមីងមមាំង បន្ទាប់មកក៏ចាំថាត្រូវញញឹម រួចបន្ទាបក្បាលរបស់គាត់ជាការគោរព។

គាត់ស្រាប់តែធ្លាក់ទឹកមុខ នៅពេលឃើញនាងកាន់ថង់ខ្មៅដែលច្រកពេញទៅដោយទូរស័ព្ទដៃទាំងសែសិបពីរគ្រឿងរបស់នាង។

ព្រឹកពេកហើយ ថ្មើរហ្នឹងផ្សារសូរិយាមិនទាន់បើកនៅឡើយទេ។ ពួកគេក៏បើកក្រវែលជុំវិញពន្លឺព្រះអាទិត្យចាំងចូលចំភ្នែករបស់ ពួកគេ។ នៅតាមផ្លូវ មនុស្សប្រុសៗកំពុងតែរុញរទេះផ្ទុកទៅដោយអីវ៉ាន់ជាច្រើន ឯខ្លះវិញស្ពាយខ្សែក្រវ៉ាត់ទាំងដុងៗចូលទៅក្នុងផ្សារធំថ្មី។ផ្សារនេះមានរាងជាដោម រចនាតាមសិល្បៈសំណង់ចាស់ គឺតាមបែបបារាំងមានពណ៌ដូចកំអួត។ សិដ្ឋមិនដែលដើរទិញអីវ៉ាន់នៅម្តុំនោះទេ។

- អ្នកនាងគួរតែទៅលេងម៉ាក់របស់អ្នកនាង - អ្នកបើកបរនិយាយ។ - អ្នកនាងដឹងទេ គាត់ស្រឡាញ់អ្នកនាងណាស់។ គ្រួសារតែងតែមកជួយយកអាសាជានិច្ចនៅពេល ដែលមានអាសន្នអន្ត្រក្រ។

ម្តាយរបស់សិដ្ឋរស់នៅប្រទេសថៃ ហើយពួកគេមិនដែលទាក់ទងគ្នាទេ។ គ្រួសាររបស់ម្តាយនាងចេះតែសុំនេះសុំនោះរហូតៈ ប្រាក់ ការណែនាំ រឺក៏ជួយរកការងារឲ្យធ្វើ។ សិដ្ឋលែងស្តីរកពួកគេទៀតហើយ។

- គ្រួសាររបស់ខ្ញុំគ្មានធ្វើអ្វីក្រៅពីនាំបញ្ហាមកនោះទេ។

អ្នកបើកបរក៏បិទមាត់ស្ងៀម ហើយបន្តបើកឡានតទៀត។

ចុងបញ្ចប់ផ្សារសូរិយាក៏បើកទ្វារឡើង។ សិដ្ឋតម្រង់ទៅហាងរបស់តារាភ្លាម ហើយចាក់ទូរស័ព្ទទាំងអស់ទៅលើតុពណ៌ខៀវ។

- តើលោកយកទាំងអស់នេះវិញបានទេ?

- ក្រុមហ៊ុនយើងធ្វើតែការដោះដូរប៉ុណ្ណោះ។ ខ្ញុំអាចប្តូរទូរស័ព្ទថ្មីជាមួយនឹងទូរស័ព្ទចាស់បាន។- តារាមើលទៅដូចជាគិតវែងឆ្ងាយណាស់។ - កុំព្រួយអី។ ទុកនៅនឹងខ្ញុំហើយ ចាំខ្ញុំយកទៅលក់ឲ្យម៉ូយម្នាក់នៅផ្សារចាស់ ហើយខ្ញុំនឹងឲ្យប្រាក់ទៅនាងនៅថ្ងៃស្អែក។- គាត់ញញឹមបែបសុទិដ្ឋិនិយម។ - ចាំខ្ញុំចាត់ការឲ្យ។

គាត់ហុចទូរស័ព្ទមួយគ្រឿងទៅវិញ ដែលអាចចាក់វីដេអូ និងបើកអ៊ីម៉ែលបាន។

- នេះគឺជាម៉ូតល្អបំផុត យកទុកប្រើចុះ។

តារាពិតជាជំនាញណាស់។ សិដ្ឋចង់តែផ្អែកខ្លួនទៅលើគាត់ដូចជាផ្អែកទៅលើខ្នើយ ហើយនៅទីនោះរហូត។ នាងអង្គុយនៅក្នុងហាងពេញមួយថ្ងៃ ដោយសម្លឹងមើលគាត់ធ្វើការ។ ប្រុសម្នាក់មកពីហាងលក់ឱសថហ្គេមនៅជាន់ខាងលើសួរថា៖

- តើនារីស្រស់ស្អាតម្នាក់នេះជានរណាដែរ?

តារាឆ្លើយតបវិញយ៉ាងមោទនៈ៖

- គឺមិត្តស្រីរបស់ខ្ញុំ។

តារាជិះម៉ូតូឌុបជូននាងទៅផ្ទះវិញ ហើយដល់ទ្វារផ្ទះរបស់នាង គាត់ក៏សើចកក្អឹក។

- ខ្ញុំមិនចង់ទៅសោះ។

នាងយកដៃខ្ទប់មាត់របិលរប៉ូចរបស់គាត់ ហើយញញឹម រួចបែរខ្លួនដើរចូលទៅក្នុងផ្ទះដោយសុភមង្គល។

នាងនៅយានដ្ឋានជាន់ផ្ទាល់ដី។ នាងឮសំឡេងម្យ៉ាងដូចជាកណ្ដុរកំពុងតែវារចុះឡើង។ នៅក្នុងកាបូបរបស់នាង ទូរស័ព្ទកំពុងតែរោទិ៍។ តើពួកអស់នេះជានរណាដែលចេះតែមកធ្វើទុកបុកម្នេញនាងរហូតហ្នឹង ក្រែងពួកគេស្លាប់អស់ហើយតើអ្វី? នាងកញ្ឆក់ទូរស័ព្ទចេញពីក្នុងកាបូបរបស់នាង ហើយចុចប៊ូតុងពណ៌ខៀវ រួចយកទូរស័ព្ទមកដាក់ត្រចៀក។ នាងរង់ចាំ។ មានសម្លេងម្យ៉ាងដូចជាខ្យល់កួច។

ក្មេងម្នាក់និយាយមករកនាង សំឡេងរបស់វាអណ្ដឺតអណ្ដកហាក់ដូចជាកំពុងយំអញ្ចឹង។ - ពួកគេចង់មេដៃរបស់ខ្ញុំផ្គួបចូលគ្នា។

សិដ្ឋសួរទាំងកំរោល។ - ម៉េចក៏ឯងស្គាល់លេខទូរស័ព្ទយើង?

- ខ្ញុំនៅតែម្នាក់ឯងទេ!

- បើអញ្ចឹង តេទៅនរណាផ្សេងទៅ។ តេទៅកាន់សមាជិកគ្រួសារឯងណាម្នាក់ចុះ។

- គ្រួសាររបស់ខ្ញុំចែកឋានអស់ហើយ។ ខ្ញុំមិនដឹងថាខ្ញុំនៅឯណាទេ។ ខ្ញុំឈ្មោះ...

សិដ្ឋបិទទូរស័ព្ទចោល។ នាងបើកគូទឡាន ហើយបោះទូរស័ព្ទចូលទៅក្នុង។ ការដែលត្រូវខ្មោចទូរស័ព្ទមករកគឺ...ពិតជា *មិនទាន់សម័យ* ទាល់តែសោះ។ តើកម្ពុជាអាចក្លាយជាប្រទេសលេខមួយយ៉ាងម៉េចនឹងកើតទៅ ប្រសិនបើប្រព័ន្ធទូរស័ព្ទក្នុងប្រទេសត្រូវខ្មោចលងយ៉ាងនេះនោះ?

នាងដើរទាំងខឹងសម្បាទៅក្នុងបន្ទប់ទទួលភ្ញៀវ។ នៅលើតុ ឆ្កែដ៏ស្អាតបាតមួយ តម្លៃ១៥០០ដុល្លារសម្លក់មើលមកនាងពីក្នុងប្រអប់ប្លាស្ទិច។ សិដ្ឋឡើងជណ្ដើរទៅលើលានដំបូលដើម្បីសម្ងំដេកឲ្យបានឆ្ងាយបំផុតពីរបស់គ្រប់ៗយ៉ាងនៅក្នុងផ្ទះតាមដែលអាចធ្វើទៅរួច។

និពន្ធដោយ៖ ជីអូហ្វ រ៉ៃមែន (Geoff Ryman)

ប្រែសម្រួលដោយ៖ *F*

នាងភ្ញាក់ឡើង មេឃងងឹតទៅហើយ ហើយឮសម្លេងគ្រូកៗពីជាន់ក្រោម។

សំឡេងនេះគឺជាសំឡេងទង្គិចនៃលោហៈ ប្រៀបបាននឹងនរណាម្នាក់ដែលត្រូវជាប់សោនៅក្នុងឡានកំពុងតែរើបម្រះ។ សិដ្ឋបើកអាយផតរបស់នាងឡើង។ មានអ្វីម្យ៉ាងស្រាប់តែធ្វើឲ្យចម្រៀងរបស់នាងលែងឮសំឡេងរលីង។ នាងដើរមើលតាមខ្សែ ហើយកញ្ឆក់ម៉ាស៊ីនចាក់ចម្រៀង ហ្សិន មួយទៀត ប៉ុន្តែវាក៏ដូចគ្នាដែរ។ មានសំឡេងមនុស្សនិយាយគ្នាជ្រៀតចូលទៅក្នុងបទចម្រៀង។

តើនាងមានស្តាប់ឮសំឡេងហែកទេ? នាងដកកាសពាក់ត្រចៀកចេញ ហើយឮស្ងរសំឡេងអ្វីមួយបន្លឺឡើងមកតាមជណ្តើរ។

ដូចជាមានសំឡេងពន្លឺម្យ៉ាងដែលរត់មិនស្មើគ្នា។ នាងនឹកឃើញទៅដល់ក្មេងៗពិការ។ ខ្លួននាងឡើងកករឹងដូចជាមានភួយទឹកកកមកគ្របពីលើ ធ្វើឲ្យនាងកម្រើកមិនរួចឡើយ។

ឆ្អែយន្តបានរត់ឮស្ងរង៉ូងៗមកលើលានដំបូល។ វាបង្អាក់ដំណើរនៅឯចុងជណ្តើរ។ ច្រមុះម៉ាស៊ីនថតរបស់វាតម្រង់មកនាង ភ្នែកគ្មានវិញ្ញានរបស់វាឡើងពណ៌ក្រហមឆេះ។

ឆ្អែយន្តនោះនិយាយដោយសំឡេងរាក់ទាក់ យ៉ាងកក់ក្តៅៈ

- ខ្ញុំឈ្មោះផល្លា។ ខ្ញុំព្យាយាមទៅទិញថ្នាំឲ្យបងស្រីរបស់ខ្ញុំ ហើយគ្រាន់តែប៉ុណ្ណឹង ពួកគេក៏សំឡាប់ខ្ញុំចោល។

សិដ្ឋព្យាយាមនិយាយថា “ទៅឲ្យឆ្ងាយ” ប៉ុន្តែបំពង់ករបស់នាងមិនព្រមកម្រើកសោះ។

ឆ្កែនោះផ្អៀងកររបស់វា។ - សូម្បីតែខ្ញុំស្លាប់ ក៏គ្មាននរណាគេដឹងដែរ។ តើបងស្រីនឹងធ្វើយ៉ាងណាចំពោះអ្នកទាំងនោះ ដែលគ្មាននរណាគេកាន់ទុក្ខឲ្យនោះ?

សំណើចផ្ទុះឡើងចេញពីខ្លួននាង ហើយសិដ្ឋឃើញខ្យល់ភាយឡើងទៅលើជាចំហាយទឹកត្រជាក់។

- ពួកយើងគ្មាននរណាម្នាក់សែនឲ្យទេ- ឆ្កែនោះស្រដី។

សិដ្ឋសើចក្អឹកៗដោយក្តីតក់ស្លុត។ - គ្មានអ្វីទេ។ ខ្ញុំមិនអាចធ្វើអ្វីបានទេ!- នាងឧទានឡើង ព្រមទាំងគ្រវីក្បាលរបស់នាង។

- នាងសើច?- ឆ្កែនោះប្រុងប្រៀបខ្លួន ហើយលោតភ្លឹបទៅក្នុងអង្រឹងរបស់នាង។ វាបែរហើយលើកកន្ទុយប្លាស្ទិចដ៏ថ្លារបស់វា រួចជុះលាមកមែនទែនដាក់ជិតខ្លួនសិដ្ឋ។ មានសក់ខ្លីៗពណ៌ត្នោតត្របាញ់នៅក្នុងលាមកនោះ តាមពិតទៅគឺជាលលាដ៍ក្បាល ដែលមានធ្មេញមនុស្សពណ៌សស្គុសមួយក្រាសញញឹមស្ញេញ។

សិដ្ឋស្រែក ហើយក្រឡាប់អង្រឹងធ្វើឲ្យនាង និងឆ្កែនោះធ្លាក់ទៅលើកំរាលឥដ្ឋ។ ឆ្កែនោះរុញច្រមុះវាទល់នឹងច្រមុះរបស់នាង ហើយចាប់ផ្តើមច្រៀងចម្រៀងកូនខ្មែរហួសសម័យមួយអំពីបក្សី។

មានអ្វីម្យ៉ាងធ្ងន់ភាយឡើងតាមជណ្តើរមករកនាង។ សិដ្ឋរងារញាក់ដោយចាញ់ត្រជាក់នៅលើកម្រាលឥដ្ឋ ហើយមិនអាចកម្រើកខ្លួនបានឡើយ។ ឆ្កែនោះបន្តច្រៀងដោយសម្លេងខ្លាំងៗ តែផ្អែមល្ហែម។ ស្រមោលដ៏ធំមួយបានលេចឡើងស្ទង់ៗមកលើចុងជណ្តើរ ឯសិដ្ឋលេបទឹកមាត់ក្អឹក ដើម្បីបញ្ឈប់សំណើចរបស់ខ្លួន និងចាប់ផ្តើមនិយាយឡើងវិញ។

- មានសំឡេងក្អួកក្អាំងនៅក្នុងឡាន តែគ្មានមនុស្សនៅក្នុងនោះទេ- អ្នកបើកបរឡានស្រដី។

សិដ្ឋដាក់ខ្លួនពោបទៅលើកម្រាលឥដ្ឋដោយធូរទ្រូង។ - គឺខ្មោច- នាងតប។ - ពួកគេត្រឡប់មកវិញហើយ។- នាងព្យាយាមបញ្ជាខ្លួនឯងឲ្យក្រោកឈរឡើង។ - ពួកយើងត្រូវចេញទៅហើយ។ តេទូរស័ព្ទទៅសណ្ឋាគារហ៊ិលតុនចុះ។ សួរមើលថាគេមានបន្ទប់ទំនេរដែររឺទេ។

នាងទាត់តុក្កតាឆ្កែនោះចុះទៅក្រោមជណ្តើរដែលនៅពីមុខនាង។ - ពួកយើងផ្លាស់ទីលំនៅឥឡូវតែម្តង។

ពួកគេទាំងអស់គ្នារៀបចំអីវ៉ាន់សព្វគ្រប់ដាក់ទៅក្នុងឡាន ទាំងញញឹញញ័រ។ ចំណែកឯផ្ទះនោះក៏ត្រូវបានប្រគល់ទៅឲ្យខ្មោចវិញសាជាថ្មីម្តងទៀត។ ខណៈពេលដែលពួកគេបើកបរចេញទៅទូរស័ព្ទដៃនោះនៅតែរោទិ៍ម្តងហើយម្តងទៀតឯគូទឡាន។

សណ្ឋាគារហ៊ិលតុនថ្មី (ដែលគ្មានពិតទេ) តាំងនៅជិតទន្លេទល់មុខពីក្រសួងសាសនា និងធម្មការ។ វាមានរាងខ្ពស់បែបបុរាណ មានសួនទឹក ចង្កៀងចងព្យួរពីពិតានធ្វើពីគ្រីស្តាល់ ព្រមទាំងដៃទ្វារធ្វើពីឈើ និងទង់ដែងនៅក្នុងជណ្តើរយន្ត។

នៅពាក់កណ្តាលយប់បែបនេះ មានតែបន្ទប់កូនក្រមុំកូនកម្លោះប៉ុណ្ណោះដែលនៅទំនេរ ប៉ុន្តែវាមានចែកជាបន្ទប់តូចមួយទៀត ទុកសម្រាប់ឲ្យអ្នកបើកបរឡាន និងប្រពន្ធគាត់ដេក។ នៅជាន់ទីម្ភៃមួយ រាត្រីចែងចាំងភ្លឺផ្លេកដោយពន្លឺ ហើយអ្វីៗគ្រប់យ៉ាងស្ងប់ស្ងាត់ទាំងអស់ ពោលជាកន្លែងដែលដាច់ស្រយាលពីប្រទេសកម្ពុជាបំផុត។

រឿងរ៉ាវក៏ស្ងប់ទៅវិញ...បានមួយរយៈ។

ជារៀងរាល់ថ្ងៃ នាង និង តារាទៅមើលកុន រឺក៏ទៅភោជនីយដ្ឋានជាមួយគ្នា។ ពួកគេក៏ទៅទិញអីវ៉ាន់ដែរ។ នាងចែកប្រាក់ឲ្យគាត់ខ្លះ ហើយគាត់ក៏ទិញខោអាវមួយកំផ្លេយ៉ាងស្រស់សង្ហាមួយទុកពាក់។ នៅពេលពួកគេទៅញ៉ាំ ប៊ីហ្គឺ នៅហាង ឡាក់គីសេវែន គាត់បាននិយាយថា៖

- បងបានប្រាប់ម៉ាក់បងរួចហើយថាបងបានទាក់ទងនឹងនារីម្នាក់។

និពន្ធដោយ៖ ជីអូហ្វ រីមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ *F*

សិដ្ឋញញឹម ហើយគិតថា៖ ហើយអូនគិតថាបងច្បាស់ជាប្រាប់គាត់ដែរថាអូនជាអ្នកមាន។

- អូនសម្រេចចិត្តនៅហ៊ីលតុនហើយ- នាងប្រាប់គាត់។

*ប្រហែលជាពួកយើងអាចរស់នៅហ៊ីលតុនបាន។* ស្នាមញញឹមដ៏ស្រស់មួយអាចនឹងឲ្យសញ្ញាណពីបំណងនេះ។

រដូវវស្សាបានបញ្ចប់ទៅហើយ។ ភ្លៀងមូសុងចុងខែឡើងពណ៌ប្រផេះ ដោយមានចំណែកពពកសនៅពីលើ ហាក់បីដូចជារលកដ៏ធំមួយដែលរៀបនឹងខ្ទាយដូច្នោះដែរ។

ខ្យល់ត្រជាក់ស្ងួតបានមកដល់។

ក្រោយចេញពីធ្វើការ តារាបានបបួលនាងទៅដើរលេងនៅតាមមាត់ទន្លេនៅមុខព្រះបរមរាជវាំង។ គាត់បានទៅក្នុងបន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់ដើម្បីស្លៀកខោអាវស៊ីវិល័យថ្មីដែលទើបនឹងទិញ ហើយសិដ្ឋក៏មានគំនិតថា៖ គាត់ចាប់ផ្តើមស្រមៃពីជីវិតពោរពេញទៅដោយប្រាក់ទៅអស់នោះហើយមើលទៅ។

ខណៈពេលដែលពួកគេដើរតាមមាត់ទន្លេ ដែលត្រូវមនុស្សម្នាឯទៀតមើលឃើញ សិដ្ឋមានអារម្មណ៍ក្តុកក្តួលខាងក្នុងខ្លួន។ មានពួកក្មេងស្ទាវៗគ្រប់ទីកន្លែង។ ពួកគេខ្លះមានសភាពគោកយ៉ាកដែលមិនគួរជាមានបញ្ហាអីទេ ប៉ុន្តែខ្លះទៀតសុទ្ធតែស្លៀកពាក់ហំហួនណាស់ គឺច្បាស់ជាកូនៗអស់លោកធំដែលធ្វើអ្វីបានស្រេចតែក្បាលចិត្តហើយ។ សិដ្ឋបែរមុខចេញភ្លាមដើម្បីគេចកុំឲ្យពួកគេមើលឃើញ។ ប៉ុន្តែតារាដល់ពេលស្លៀកខោអាវពណ៌ត្នោតខ្ចីថ្មី មើលទៅហាក់ដូចជាម្នាក់ក្នុងចំណោមពួកអ្នកមានទាំងនោះដែរ ហើយកូនលោកធំទាំងនោះងក់ក្បាលដាក់គាត់ដោយជ្រួញចិញ្ចឹម ហាក់ឆ្ងល់ថាគាត់ជានរណា។

នៅពីមុខរាជវាំង មានរោងពន្លាមួយដែលលយចេញពីលើទឹក។ នៅជាប់នោះមានវង់ភ្លេងប្រពៃណីមួយកំពុងតែគោះ និងផ្លុំជាតន្ត្រីសម័យបុរាណម្យ៉ាង។ មនុស្សជាច្រើនរយនាក់ត្រៀបត្រាគ្នាជុំវិញវត្តតូចមួយ។ តារាកន្ត្រាក់ដៃសិដ្ឋ ហើយពួកគេខំប្រឹងជំទើតអើតមើល។

អ្នកផងទាំងពួងនាំគ្នាកាន់ផ្កាឈូកម្នាក់មួយបាច់ៗ ព្រមទាំងទានធូបយកទៅសែន។ ពួកគេត្រវែងបាច់ឈូកទាំងនោះចូលទៅក្នុងវត្ត។ ព្រះសង្ឃក៏ចាប់ផ្តើមបោសសំអាតកំទេចឈើ និងផ្កាចេញពីខាងក្រោយរោងភ្លាម។

នៅខាងក្រោយវត្ត ពួកក្មេងៗស្លៀកពាក់អាវយឺតខោខ្លីប្រឡាក់ប្រឡូសយ៉ាងកខ្វក់កំពុងតែជីកកកាយផ្កាងាប់ៗ កំទេចកំទីធូប និងសំបកដូងចាស់ៗ។

សិដ្ឋសួរថា៖

និពន្ធដោយ៖ ជីអូហ្វ រីមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ *F*

- ហេតុអ្វីបានជាពួកគេធ្វើអញ្ចឹង?

- អូនពិតជាមិនដឹងអីមែន!- តារាសើច ហើយគ្រវីក្បាល។ ល្ងាចនោះផ្ទៃមេឃខៀវស្រឡះ ចាំងជះដោយពន្លឺសែងសូរិយា។ សិដ្ឋគិតថានាងមិនចង់ត្រឡប់ទៅសណ្ឋាគារនោះទៀតទេ ហើយកន្លែងតែមួយគត់ដែលនាងមានអារម្មណ៍រីករាយបំផុតនោះគឺនៅក្បែរតារា។ នៅជុំវិញគំនិតនោះសុទ្ធតែរបស់ខ្មៅងងឹត និងច្របូកច្របល់។

តារាស្នើសុំដោយស្មោះសរថាពួកគេគួរតែរៀបការ។

មើលទៅហាក់ដូចជាសិដ្ឋបានត្រៀមចម្លើយរួចមកហើយ។ - ទេ ច្បាស់ជាមិនបានឡើយ- នាងនិយាយភ្លាម។ - ម៉េចក៏បងសួរអញ្ចឹង? បងគ្មានទាំងបានសួរនាំនរណាម្នាក់ផងហ្នឹង! តើបងបានពិភាក្សាគ្នាជាមួយគ្រួសារបងអំពីខ្ញុំហើយរឺនៅ? តើគ្រួសាររបស់បងបានធ្វើការត្រួតពិនិត្យពីប្រវត្តិខ្ញុំឲ្យច្បាស់លាស់ទេ?

នោះគឺជាអ្វីដែលនាងចង់ដឹងជាងគេ។

តារាគ្រវីក្បាល។ - បងបានពន្យល់ថាអូនជាក្មេងកំព្រា ប៉ុន្តែពួកគាត់មិនព្រួយបារម្ភពីរឿងនោះទេ។ ពួកយើងសុទ្ធតែមនុស្សចេះដឹងខុសត្រូវ។ ពួកគាត់នឹងសប្បាយចិត្តដរាបណាដែលបងសប្បាយចិត្ត។

- ពួកគាត់នឹងមិនសប្បាយចិត្តទេ! ពួកគេត្រូវតែធ្វើការឆែកមើលសិន។

សិដ្ឋជ្រួញចិញ្ចើម។ នាងបានចិត្តភ្លាម។ - យ៉ាងហោចណាស់ក៏ពួកគេត្រូវទៅឲ្យគ្រូទាយដែរ។ ពួកគេមិនមែនជាមនុស្សល្ងង់ទេ។ ខ្ញុំអាចជួយពួកគេបាន។ សួរពួកគេទៅមើល ថាតើគ្រូទាយណាដែលពួកគេទុកចិត្ត។

តារាញញឹមទាំងអឹមអៀន។ - ពួកយើងគ្មានប្រាក់ទេ។

- ចាំអូនឲ្យប្រាក់ ហើយបងប្រាប់ពួកគាត់ចុះថាបងជាអ្នកចេញលុយ។

កែវភ្នែករបស់តារាសម្លឹងមកមើលមុខនាង។ - បងមិនចង់បានដូច្នោះទេ។

- តើយើងម៉េចនឹងអាចដឹងបានថាវាជាអាពាហ៍ពិពាហ៍ដែលមានសុភមង្គលនោះ? ចំណែកម្តាយដ៏កំសត់របស់បងវិញ តើបងម៉េចនឹងអាចសុំឲ្យគាត់ធ្វើការសម្រេចចិត្តដូច្នេះបាន ដោយគ្មានការអះអាងអ្វីបន្តិចនោះ? អញ្ចឹង បងឯងចាំសួរគ្រួសារបងឯងពីឈ្មោះ អ្នកជំនាញណាម្នាក់ដែលពួកគាត់ទុកចិត្ត ហើយចាំឲ្យអូនចេញលុយ។ រួចអូនទៅជួបគ្រូទាយផ្ទាល់ខ្លួនរបស់នាយករដ្ឋមន្ត្រីហ៊ុន សែន និងអាលផ្ទៀងផ្ទាត់លទ្ធផលគ្នាមើល៉។

ធ្វើដូច្នេះ នាងអាចបង្ហាញម្តងទៀតនូវភាពគួរសម និងភាពមានបានរបស់នាង។

និពន្ធដោយ៖ ជីអូហ្វ រីមែន (Geoff Ryman)

ប្រែសម្រួលដោយ៖ *F*

នៅក្នុងរឿងស្នេហាចាស់បុរាណ តែកាលណាឪពុកម្ដាយមិនយល់ព្រម នោះគ្រូទាយនឹងនិយាយថាអាពាហ៍ពិពាហ៍នេះនាំប្រផ្នូលមិនល្អ។ សិដ្ឋគ្មានខ្វល់ពីរឿងនេះទេ។

នាងព្រមឲ្យគ្រូទាយនូវអ្វីៗគ្រប់យ៉ាងដែលពួកគេត្រូវការ មានឡាន ដីស្រែ ហើយចង់បានតែលទ្ធផលទស្សន៍ទាយរបស់ពួកគេតែប៉ុណ្ណោះ។ ពួកគេទាំងអស់គ្នាសុទ្ធតែយល់ស្របថាមង្គលការនេះពិតជានាំប្រផ្នូលល្អណាស់។

បន្ទាប់នាងទៅបញ្ជាក់បន្ថែមទៀតដោយទៅជួបគ្រូទាយរបស់នាយករដ្ឋមន្ត្រី។

គ្រូទាយរបស់ហ៊ុន សែនគឺជាស្ត្រីម្នាក់ស្លៀកពាក់ឈុតខ្មៅ។ គាត់មានក្រចកវែងៗដូចក្រញាំសត្វ ប៉ុន្តែក្រចកទាំងនោះសុទ្ធតែត្រូវបានធ្វើ និងលាបពណ៌សយ៉ាងល្អឥតខ្ចោះ។

គាត់គឺជាប្រភេទគ្រូទាយដែលត្រូវឲ្យព្រលឹងចូលសណ្ឋិត។ គាត់អង្គុយនៅនឹងតុ ហើយសម្លឹងមើលសិដ្ឋមិនព្រិចភ្នែកដូចជាត្រី ឯដៃគាត់ទាំងពីរផ្គួបចូលគ្នា។ ក្រោយពីនិយាយសួរនាំគ្នាបន្តិចបន្តួចមក គាត់ក៏ប្រកាស។

- យកតែប្រាក់ដុល្លារប៉ុណ្ណោះ។ គឺតម្លៃប្រាំពាន់។ ខ្ញុំត្រូវការទិញផ្ទះល្វែងមួយឲ្យកូន។

- ដូចជាថ្លៃខ្ពស់ណាស់- សិដ្ឋតប។

- នេះមិនមែនជាថ្លៃទាយទេ។ វាគ្រាន់តែជាការពិចារណាយល់ព្រមនឹងទស្សន៍ទាយឲ្យនាងតែប៉ុននោះ។ ថ្លៃទាយនោះត្រូវគិតតម្លៃប្រាំពាន់ដុល្លារទៀត។

ពួកគេចាប់ផ្ដើមតថ្លៃគ្នា។ សិដ្ឋចូលចិត្តចរិតរបស់ គ្រូទាយនេះណាស់។ វាបានបញ្ជាក់នូវអ្វីៗគ្រប់យ៉ាងដែលសិដ្ឋយល់ឃើញពីជីវិត។

ថ្លៃទាយត្រូវបានបញ្ចុះខ្លះ តែថ្លៃពិចារណាមិនចុះឡើយ។

- ឲ្យប្រាក់ជាមុន- គ្រូទាយនោះស្រដី។ គាត់មិនព្រមយកសែកឡើយ គឺយកតែប័ណ្ណឥណទានបរទេសប៉ុណ្ណោះ ដូចជានៅភោជនីយដ្ឋានល្អៗបំផុតដូច្នោះដែរ។ ប័ណ្ណស៊ីសរបស់សិដ្ឋមានប្រសិទ្ធិភាពភ្លាម។ វាមានឥណទានមិនកំណត់ ទុកប្រើក្នុងករណីដែលនាងត្រូវចាកចេញពីប្រទេសដោយប្រញាប់ប្រញាល់។

គ្រូទាយនោះបន្លឺឡើងថា៖

- ខ្ញុំនឹងប្រាប់គ្រួសាររបស់ខាងប្រុសថាមង្គលការនេះពិតជាចំរុងចំរើនជាពិសេស។

សិដ្ឋចាំច្បាស់ណាស់ថា នាងមិនទាន់បាននិយាយអ្វីអំពីខាងប្រុស គ្រួសារ រឺក៏មង្គលការអ្វីនោះទេ។

គ្រូទាយនោះញញឹម។ - ខ្ញុំដឹងថានាងមិនចាប់អារម្មណ៍នឹងចង់ដឹងពីហោរាពិតប្រាកដនោះឡើយ។ ប៉ុន្តែប្រាប់នាងដោយមិនគិតលុយយកបុណ្យទៅចុះ អាពាហ៍ពិពាហ៍នេះពិតជាមង្គលណាស់។ ទោះជាមិនសូកលុយ គ្រូហោរដទៃទៀតក៏នឹងនិយាយដូចគ្នាអញ្ចឹងដែរ។

កែវភ្នែករបស់គ្រូទាយនោះចាំងពន្លឺផ្លេកៗទំនងជាមិនរីករាយ។ - ដូច្នេះនាងមិនចាំបាច់ត្រូវទិញវាលស្រែឲ្យគ្រូហោរអស់នោះ ហើយក៏មិនត្រូវការបង់ឲ្យខ្ញុំនូវប្រាក់ថ្លៃប្រាំពាន់ដុល្លារបន្ថែមទៀតនោះដែរ។

គាត់ឈ្ងោកមើលក្រចកដ៏ប្រណិតរបស់គាត់។ - នាងច្បាស់ជានឹងមានសុភមង្គលណាស់។ ប៉ុន្តែជីវិតរបស់នាងនឹងត្រូវក្រឡាប់ចាក់ជាមុន។

ខ្នងដៃរបស់សិដ្ឋចាប់ផ្ដើមព្រឺដូចជាចាញ់រងា។ ពេលនោះនាងគួរតែខឹង ប៉ុន្តែបែរជាញញឹមទៅវិញ។ ហេតុអ្វី?

ហើយហេតុអ្វីបានចាំបាច់ត្រូវខ្វះខ្វាយសុជីវធម៌ទៅលើស្រីធ្មប់កញ្ចាស់ម្នាក់នេះ? សិដ្ឋបែរដើរចេញទៅដោយគ្មាននិយាយលាគ្នាមួយម៉ាត់។

- អូ! ហើយចំនែកបញ្ហារបស់នាងមួយទៀត- ស្ត្រីនោះពោល។

សិដ្ឋបែរមុខមកក្រោយ ចាំស្ដាប់។

- សត្រូវ- គ្រូទាយនោះបន្ត - អាចប្រែក្លាយមកជាមិត្តវិញបាន។

សិដ្ឋដកដង្ហើមធំ។ - តើអ្នកកំពុងតែនិយាយពីអ្វីហ្នឹង?

ស្នាមញញឹមរបស់គ្រូទាយ រីកធំដូចអង្គប់ដាក់ខ្លា។ - គឺនិយាយពីមនុស្សមួយលាននាក់ដែលឪពុកនាងបានសម្លាប់។

សិដ្ឋប្រែជាលែងគួរសម។ - មិនមែនមួយលានទេ- នាងនិយាយ។ - គឺប្រហែលជានៅចន្លោះពីពីររយហាសិបពាន់ ទៅប្រាំរយពាន់។

- បានហើយ- គ្រូទាយនោះញញឹម។ - ពុករបស់ខ្ញុំក៏នៅក្នុងចំណោមនោះដែរ។- គាត់នៅបន្តញញឹមយូរបន្តិចទៀត។ -ខ្ញុំច្បាស់ជានឹងប្រាប់លោកនាយករដ្ឋមន្ត្រីថា ឯងបានមករកខ្ញុំ។

សិដ្ឋបន្លឺសម្លេងបែបមិនពេញចិត្ត។ - ចាំខ្ញុំប្រាប់គាត់ខ្លួនឯងតែម្ដង។

ប៉ុន្តែនាងរត់ត្របាញ់ទៅរកឡានរបស់នាងវិញ។

នារាត្រីនោះ សិដ្ឋសម្លឹងមើលមកក្រោមឃើញពន្លឺទាំងអស់នោះប្រៀបបាននឹងត្បូងពេជ្រ។ នាងដាក់ខ្លួនទៅលើកន្ទេល ហើយបើកអាយផតស្ដាប់។

នរណាម្នាក់ស្រាប់តែចាប់ផ្តើមស្រែកដាក់នាង។ នាងទាញកាសស្តាប់ត្រចៀកចេញ ហើយលោតទៅរកបង្អួច តែវាមិនព្រមបើកសោះ។ នាងក៏អង្រួនវា ហើយចាប់ទាញស៊ុមបង្អួចនោះរហូតទាល់តែវាបង្ហើបបានបន្តិច រួចនាងគ្រវែងអាយផតនោះពីបង្អួចជាន់ទីម្ភៃមួយ។

នាងដេករាងថ្ងៃជ្រុល ពេលភ្ញាក់ឡើង ស្រាប់តែឮសំឡេងទូរទស្សន៍។ នាងបើកទ្វារឡើង ហើយឃើញចូវ៉ានី កំពុងតែផ្អែកខ្លួននឹងជញ្ជាំង។

- ទូរទស្សន៍នោះ....- ចូវ៉ានីស្រដី ភ្នែកបើកក្រឡោតៗដោយក្តីតក់ស្លុត។

អ្នកបើកបរឡានរង់ចាំនៅជិតនឹងបង្វេចខោអាវរបស់គាត់។ គាត់ក្រោកឈរឡើង ទឹកមុខក្រៀមក្រំដូចជាផ្លែប្រមាញ់។

នៅលើអេក្រង់ទូរទស្សន៍ មានចាក់បញ្ចាំងវីដេអូចម្រៀងខារ៉ាអូខេ។ ទាស់ត្រង់ថាចម្រៀងនោះហួសសម័យណាស់ទៅហើយ។ ហេតុអ្វីបានជាវីដេអូចម្រៀងនោះបង្ហាញរូបបុរសអត់ឃ្លានម្នាក់កំពុងតែលួចហូបពោតនៅនៅក្នុងចំការអញ្ចឹង? គាត់ងាកមើលក្រោយទាំងញញើតពេលគាត់កំពុងតែហូប។ ចម្រៀងនោះគឺជាចម្រៀងដែលផ្អែតុក្កតាច្រៀងនៅចុងជណ្តើរ។ បុរសអត់ឃ្លាននោះងើយមើលមកសិដ្ឋ ហើយកំទេចគ្រាប់ពោតរមៀលធ្លាក់ចេញពីមាត់របស់គាត់។

- វាអញ្ចឹងឯង- អ្នកបើកបរបន្លឺឡើង។ - ខ្ញុំដកឌុយចេញ ប៉ុន្តែវានៅតែចាក់បញ្ចាំងបទហ្នឹងនៅគ្រប់ប៉ុស្តិ៍។- គាត់លើកដៃសំពះ តែមើលទៅដូចជាវេទនាណាស់។ - ប្រពន្ធរបស់ខ្ញុំចង់ចាកចេញទៅហើយ។

សិដ្ឋមានអារម្មណ៍ខ្មាសខ្លួនឯង។ វាពិតជាវេទនា និងអាក្រក់ណាស់ ដែលត្រូវខ្មោចតាមញាំញីមិនចេះចប់មិនចេះហើយ។ បើពួកគេមិនចង់ទៅ ទើបចម្លែក។

- មិនអីទេ។ ខ្ញុំអាចជិះឡានឈ្នួលបាន- នាងតប។

អ្នកបើកបរងក់ក្បាល ហើយដើរចូលទៅបន្ទប់ជាប់នោះ ព្រមទាំងខ្សឹបដាក់ប្រពន្ធគាត់។ ដោយមានការរុះរើបន្តិចបន្តួច ពួកគេបានប្រមែប្រមូលរបស់របររួចរាល់។ ពួកគេលើកដៃសំពះ រួចសូមអភ័យទោស។

សំឡេងទ្វារបិទយ៉ាងថ្នមៗស្ទើរតែមិនឮ។

សិដ្ឋគិតថាវានឹងនៅតែអញ្ចឹងជារៀងរហូត។ ទោះបីជាខ្ញុំទៅទីណាក៏ដោយ។ វាក៏នឹងនៅតែអញ្ចឹងដែរទោះជានាងនៅក្បែរតារាភក្តិ។

ទូរស័ព្ទសណ្ឋាគារចាប់ផ្ដើមរោទិ៍។ សិដ្ឋទុកឲ្យវារោទិ៍ចោល។ នាងយកភួយទៅគ្របទូរទស្សន៍ ប៉ុន្តែសំឡេងចម្រៀងតូចឆ្មារដ៏គួរឲ្យព្រឺសំបុរនោះនៅតែឆ្លៀតរកច្រកចេញមកដល់ត្រចៀករបស់នាង ចំនែកនាងអង្គុយនៅគែមគ្រែ សំឡឹងមើលទៅក្នុងលំហទទេរ។

*ខ្ញុំត្រូវតែចាកចេញពីប្រទេសកម្ពុជា។*

នៅឯផ្សារ សិដ្ឋមើលទៅហាក់ដូចជារីករាយខុសសព្វដង។ គ្រូទាយទាំងអស់សុទ្ធតែប្រកាសថាមង្គលការនេះគឺជាប្រផ្នូលល្អ។ ម្ដាយរបស់គាត់ថែមទាំងបានអញ្ជើញសិដ្ឋទៅលេងផ្ទះនៅថ្ងៃបុណ្យភ្ជុំបិណ្ឌទៀតផង។

- ពួកយើងអាចជិះឡានក្រុងទៅនៅថ្ងៃស្អែក- គាត់ស្រដី។

- តើលើឡានក្រុងធុំក្លិនអាក្រក់ទេ? បើមានមនុស្សជិះពេញៗអញ្ចឹង?

- ធុំតែក្លិនម៉ាស៊ីនត្រជាក់ប៉ុណ្ណោះ។ បន្ទាប់មកចាំយើងជិះឡានឈ្នួល ហើយដើរតាមផ្លូវលំចូលទៅ។- តារាស្រាប់តែសើចរីតតែខ្លាំងឡើងទ្វេ។ - អូ្ហ! ច្បាស់ជាល្អសម្រាប់អូនឯងជាមិនខាន។

- តើនឹងមានធូលីទេ?

- មានគ្រប់ទីកន្លែង! អូ! ស្បែកជើងកីឡាដ៏កខ្វក់របស់អូនឯងច្បាស់ជាកាន់តែមានតម្លៃ!

សិដ្ឋគិតថា យ៉ាងហោចណាស់ក៏គ្មានទូរទស្សន៍ រឺក៏ទូរស័ព្ទដែរ។

ពីរថ្ងៃក្រោយមក សិដ្ឋកំពុងតែដើរតាមផ្លូវលំដីហុយមួយ ដើរបណ្ដើរអោនគេចមែកឈើបណ្ដើរ។ ធូលីដីប្រឡាក់ពេញស្បែកជើងរបស់នាង។ តារាដើរតាមពីក្រោយនាងបណ្ដើរ សើចបណ្ដើរ ដែលនាងយល់ថាគាត់ក៏ខ្លាចដូចជានាងដែរ។

នាងស្ដាប់ឮសំឡេងក្រឹកៗដ៏ចម្លែកមួយ។ - សំឡេងអីហ្នឹង?

- គឺសត្វពពែ- គាត់ឆ្លើយ។ - ម្ដាយបងទិញវាឲ្យបងនៅខែមេសាទុកជាអំណោយ។

ពពែមួយក្បាល។ អ្នកជនបទពិតជាអ្នកជនបទមែន! សិដ្ឋមិនដែលបានឃើញពពែឡើយ។ នាងមិនទាំងដែលចង់ឃើញម្ដងណាសោះ។

តារាពន្យល់។ - បងបានលក់ពួកវាឲ្យទៅពួកមូស្លីម។ វាគឺជាជំនួញដោះដូរគ្នាខាងផ្នែកកសិកម្ម។

មានដើមឈើនៅគ្រប់ទីកន្លែង ដែលជះស្រមោលមកលើដីដូចជាពស់វារ។ សិដ្ឋមានអារម្មណ៍ចង់តែក្អួត។ នាងសន្យាចំពោះខ្លួនឯង *តែល្ងីកណាឃើញមូសសូម្បីតែមួយក្បាលគត់ នាងច្បាស់ជាស្រែក និងរត់ចេញទៅវិញមួយរំពេច។*

និពន្ធដោយ៖ ជីអូហ្វ រីមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ *F*

ផ្ទះនោះមានទំហំតូច តាំងនៅលើសសរបញ្ឈរតូចៗផ្គួបចូលគ្នា។ នាងខំតែនឹកជាមុនថាជាផ្ទះជនបទដ៏ធំស្កឹមស្កៃមួយដែលតាំងខ្ពស់ពីដីទ្រដោយសសរបេតុង ហើយមានស្នាមឆ្លាក់រូបពន្លឺព្រះអាទិត្យនៅលើហោជាង។ ផ្ទះបាយគឺជាខ្ទមមួយដែលនៅផ្ទាល់រាបនឹងដី គ្មានចន្ទល់ ហើយសាងសង់ពីស្លឹកត្នោត ឯអគ្គិសនីក៏អត់មានដែរ។ ពន្លឺមួយឆ្វេចនៅនឹងពិតានគឺបានមកពីភ្ជាប់នឹងអាគុយឡាន ហើយពួកគេតែងតែដុំភ្លើងឲ្យឆេះចោលជាប់ជានិច្ចនៅលើតុធ្វើពីបេតុងទុកសម្រាប់ចម្អិនម្ហូប។ អ្វីៗគ្រប់យ៉ាងសុទ្ធតែធុំក្លិនត្រីខ្លោច។

សិដ្ឋចូលចិត្តបែបនេះណាស់។

នៅខាងក្នុងខ្ទមនោះ ផ្សែងដែលចេញពីភ្លើងរមែងបណ្តេញមូសឲ្យនៅឆ្ងាយបាន។ ម្តាយរបស់តារា ឈ្មោះអ្នកស្រី នុន គន្ធា ស្វាគមន៍នាងដោយស្នាមញញឹម។ ប្រការនេះធ្វើឲ្យសិដ្ឋលើកដៃសំពះយ៉ាងសមគួរតបទៅវិញ ពោលជាការសំពះដែលកើតឡើងដោយឥតព្រៀងទុកជាមុន។ នៅលើតុមានថង់ប្លាស្ទិចមួយដាក់សុទ្ធតែព្រោនស្ងួត។

ដោយគ្មានគិតអ្វីទាំងអស់ សិដ្ឋដាក់ខ្លួនអង្គុយចុះនៅនឹងតុ ហើយចាប់ផ្តើមបកសំបកព្រោនទាំងនោះចេញ។

*ហេតុអ្វីបានជាខ្ញុំធ្វើអញ្ចឹង?*

*ពីព្រោះវាគឺជាអ្វីដែលខ្ញុំតែងធ្វើនៅផ្ទះ។*

សិដ្ឋស្រាប់តែនឹកឃើញទៅដល់តំបន់ការពារនៅក្នុងព្រៃ ដែលជាតំបន់ដាក់របងការពារព័ទ្ធជុំវិញរាងរង្វង់។ ប៉ាដេកនៅផ្ទះមួយ ហើយស្រីៗដេកនៅផ្ទះមួយទៀត។ សិដ្ឋតែងតែនិយាយលេងជាមួយនឹងចុងភៅ។ ដោយអត់ការធ្វើ នាងក៏ជួយចិតបន្លែ រឺក៏បកសំបកព្រោន។ បន្ទាប់មក ប៉ារមែងមកស្រស់ស្រូបអាហារ ហើយគាត់នឹងអង្គុយចុះ រួចលើកនាងតូចសិដ្ឋដាក់នៅលើភ្លៅ។

បងប្រុសរបស់តារាឈ្មោះ យុទ្ធ បានត្រលប់មកវិញដើម្បីទទួលទានអាហារថ្ងៃត្រង់។ គាត់មានក្បាលពោះកំប៉ោង ហើយបើកឡានឈ្នួលដើម្បីលៀងជីវិត ហើយគាត់ដើរដោយដំណើរធ្ងន់ៗដូចជាមនុស្សចាស់ពេលមួម៉ៅដូច្នោះដែរ។ គាត់ឈោងយកអង្ករ ធ្វើឲ្យសិដ្ឋធុំក្លិនក្លៀករបស់គាត់។

- នាងឃើញពីរបៀបរស់នៅរបស់ពួកយើងហើយ- យុទ្ធស្រដីមកកាន់សិដ្ឋ។ - នេះហើយគឺជាអ្វីដែលយើងទទួលបានដោយសារតែរើសអ្នកដឹកនាំខុស។ សីហនុយល់ថាពួកយើងជាអ្នកប្រឆាំងនឹងរបបរាជាធិបតេយ្យ។ ចំពោះហ៊ុន សែនវិញ យើងគឺជាសត្រូវចំតួតែម្តង។ មាននៅចាំកម្មវិធី “ធ្វើការដើម្បីប្រាក់” ដែរទេ?

ទេ។

និពន្ធដោយ៖ ជីអូហ្វ រ៉ៃមែន (Geoff Ryman)

ប្រែសម្រួលដោយ៖ *F*

- ពួកគេគ្មានបានប្រគល់ការងាររស់នោះឲ្យពួកយើងធ្វើទេ។ ពួកយើងប្រហែលជាស្រដៀងនឹងពួកខ្មែរក្រហមដែរហើយមើលទៅ!

សិដ្ឋសញ្ជឹងគិតក្នុងចិត្ត៖ *អតីតកាល...ហេតុអ្វីបានជាពួកគេមិនព្រមបំភ្លេចវាចោលទៅ? ហេតុអ្វីបានជានៅអួតអាងអំពីសង្គ្រាមចាស់ៗរបស់ពួកគេទៀត?*

អ្នកស្រី នុន គន្ធា សើចគឃឹកដោយក្ដីស្រឡាញ់។ - កូនប្រុសច្បងរបស់មីងកើតមកតែងតែឆេវឆាវអញ្ចឹងឯង- គាត់និយាយ។ - ពាក្យស្លោកប្រចាំខ្លួនរបស់វាគឺ “អ្នកក្លាហានចាំដប់ឆ្នាំសងសឹកក៏មិនយឺតពេលដែរ”។

យុទ្ធចាប់ផ្ដើមនិយាយបន្តទៀត។ - ពួកគេយកចិត្តទុកដាក់នឹងអាបិសាចកញ្ចាស់ប៉ុល ពតនោះជាជាងពួកយើងទៅទៀត។ ប៉ុន្តែថាមិនបានដែរ ព្រោះអីកាលនោះគាត់ជាជនសំខាន់ម្នាក់។ ប្រសិនបើនាងបានទៅមើលផ្នូររបស់គាត់នៅអន្លង់វែង នាងនឹងឃើញថា នៅតែមានមនុស្សដាក់របស់សែនឲ្យគាត់ទៀត! ពួកគេថែមទាំងសុំលេខឆ្នោតពីគាត់ទៀតផង!

គាត់តម្រង់មួកហួសសម័យពណ៌បៃតងដ៏ទន់របស់គាត់ដាក់ពាក់លើក្បាល ហើយនិយាយ៖

- រីករាយដែលបានជួបនាង សិដ្ឋ។ តារា នាងដូចជាមានវណ្ណៈខ្ពស់មិនសក្តិសមនឹងឯងសោះ។- ប៉ុន្តែគាត់និយាយពាក្យទាំងនេះទាំងស្នាមញញឹម។ រួចគាត់ក៏ងើបបង្វែរខ្លួនចាកចេញទៅ។

ចានក្បានបានប្រមែប្រមូលជុំគ្នាអស់ហើយ។ ម្ដងទៀតហើយដោយគ្មានគិតអ្វីទាំងអស់ សិដ្ឋស្រាប់តែចាប់លាងសំអាតធុងទឹក ហើយលើកវាយកទៅដាក់នៅឯមែកឈើដែលឆេះខ្លោចឡើងខ្មៅ។ គេយកចានទៅលាងនៅនឹងទឹកថ្លុកនោះ ពីព្រោះទឹករីងអស់ហើយ។

- នាងមិនគួរធ្វើការទេ- ម្ដាយតារាពោល។ - នាងគឺជាភ្ញៀវណា៎។

- ខ្ញុំធំឡើងនៅក្នុងជំរំជនភៀសខ្លួន ធ្លាប់ទៅហើយ- សិដ្ឋតប។ ទោះជាយ៉ាងណា ក៏នេះជាការពិតដែរ។

តារាសម្លឹងមើលមកនាង ក្នុងចិត្តលាយឡំនូវក្ដីស្រឡាញ់ មោទនភាព និងសេចក្ដីដឹងគុណដោយមានសំណាងទទួលបានប្រពន្ធអ្នកមានម្នាក់ដែលចេះធ្វើការផ្ទះ។

ហើយសិដ្ឋក៏មិនប្រាថ្នាចង់បានអ្វីឲ្យលើសពីនេះដែរ។ បានគ្រួសារប៉ុណ្ណឹងគឺសមល្មមសំរាប់នាងណាស់ហើយ។

នៅរសៀលថ្ងៃជ្រេ បងប្អូនប្រុសទាំងបួននាក់បានមកលេងជាមួយនឹងប្រពន្ធរបស់ពួកគេនៅចុងថ្ងៃបុណ្យភ្ជុំបិណ្ឌ ជាពេលដែលព្រលឹងអ្នកដែលស្លាប់ទៅអាចដើរហើរនៅលើលោកនេះបាន។

មនុស្សម្នានាំគ្នាបាចអង្ករនៅជុំវិញព្រះវិហារដើម្បីឧទ្ទិសដល់ក្រុមគ្រួសាររបស់ពួកគេ។ ខ្មោចខ្លះមានមាត់តូច ដូច្នេះគេក៏បាចអង្ករពិសេសឲ្យពួកគេ។

សិដ្ឋមិនដែលចូលរួមពិធីបុណ្យភ្ជុំបិណ្ឌម្តងណាទេ។ តើនាងម៉េចនឹងអាចទៅវិហារ ហើយបាចអង្ករឲ្យប៉ុល ពតទៅ?

ក្រុមគ្រួសារនោះប្រជុំគ្នានៅក្នុងផ្ទះបាយ ហើយនិយាយគ្នាលេង។ ពេលវេលាទាំងនោះហាក់ដូចជាមានសភាពស្រពិចស្រពិលទាំងស្រុងសម្រាប់សិដ្ឋ។ អ្នកឯទៀតៗសុទ្ធតែមានគ្រួសារផ្ទាល់ខ្លួនដែលពួកគេផ្តល់កិត្តិយសអោយ។ ដោយក្តីភ្ញាក់ផ្អើលចំពោះសិដ្ឋ ឪពុកមាម្នាក់នោះបានលើកយោបល់ថាពួកគេគួរតែសរសេរឈ្មោះអ្នកដែលស្លាប់ទៅ ហើយដុតចោល ដើម្បីជាការឧទ្ទិសជូនកុសលផលបុណ្យ។ វាគ្មានអ្វីពាក់ព័ន្ធនឹងបុណ្យភ្ជុំបិណ្ឌទេ ប៉ុន្តែក៏ជាគំនិតល្អម្យ៉ាងដែរ ដូច្នេះក្រុមគ្រួសារទាំងអស់ក៏ចាប់ផ្តើមសរសេរឈ្មោះដាក់លើក្រដាសម្នាក់មួយសន្លឹកៗ។

សិដ្ឋអង្គុយ ដៃជាប់គាំងមិនដឹងជាសរសេរអ្វី។

ម្តាយរបស់តារាក៏សាកសួរៈ

- តើគ្មានឈ្មោះដែលឯងចង់សរសេរទេវី សិដ្ឋ?

- ទេ- សិដ្ឋនិយាយដោយសំឡេងស្ងួត។ តើនាងម៉េចនឹងអាចសរសេរឈ្មោះ ប៉ុល ពត ទៅ? គាត់ពិតជានាំនរកមកលើផែនដីយ៉ាងច្បាស់ប្រាកដណាស់។ - គ្មាននរណាទេ។

តារាត្រដុសដៃរបស់នាង។

- ប្រាកដជាមាន សិដ្ឋ។ ជាឈ្មោះដ៏ពិសេសមួយ។

- ទេ អត់មានទេ។

តារាគិតថា នាងមិនចង់ឲ្យអ្នកដទៃដឹងថាឪពុករបស់នាងគឺ កុល វីរៈបុត្រ ទេ។ គាត់ក៏ខ្សឹបប្រាប់នាង។

- បងសន្យា។ គ្មាននរណាមើលឃើញទេ។

ដង្ហើមរបស់សិដ្ឋក៏ចាប់ផ្តើមញ័រ។ នាងយកក្រដាសនោះឡើងមក ហើយក៏ចាប់ផ្តើមយំតែម្តង។

- អូ!- ម្តាយតារាឧទានឡើង ដោយក្តីអាណិតអាសូរ។ - អ្នករាល់គ្នានៅក្នុងប្រទេសនេះតែងតែមានសោកនាដ្យកម្មរបស់ខ្លួន។

សិដ្ឋក៏សរសេរឈ្មោះ កុល វីរៈបុត្រ។

តារាយកក្រដាសនោះ មូរ ហើយសម្លឹងមើលមកភ្នែកសិដ្ឋ។ គាត់ហាក់ដូចជាចង់និយាយថា *អូនឃើញទេ? បងបានលាក់ការសម្ងាត់របស់អូនជិតណាស់។* រួចក៏យកក្រដាសនោះទៅដុតទៅ។

ផ្គរលាន់បានបន្លឺឡើងទាំងផ្ទៃមេឃស្រឡះ។ អំបាញ់មិញនៅភ្លឺស្រឡះល្អ ប៉ុន្តែភ្លៀងស្រាប់តែបង្អុរចុះមកប្រៀបបាននឹងវាំងននដែលធ្លាក់ចុះគ្របជិតផ្លូវចូលផ្ទះ។ ខ្យល់មិនដឹងជាមកពីណា ស្រាប់តែបក់បោកជញ្ជាំងធ្វើពីស្លឹកត្នោត ហាក់ដូចជាចង់ហែកផ្លូវចូល។

គ្រួសារនោះស្រែកហៅគ្នីគ្នា ហើយសើចគឹល ទុកឲ្យតំណក់ទឹកភ្លៀងស្រក់ជោកលើស្មារបស់ពួកគេ ទើបពួកគេនាំគ្នាក្រោកឡើងរុញជញ្ជាំងឲ្យងាកមកក្រោយបន្តិច ដើម្បីបាំងកុំឲ្យភ្លៀងសាចចូល។

ប៉ុន្តែសិដ្ឋដឹងច្បាស់ណាស់ថាសត្រូវរបស់ឪពុកនាងស្ថិតនៅក្នុងផ្ទះបាយនោះឯង។

ភ្លៀងរាំង ឯព្រះអាទិត្យក៏បញ្ចេញពន្លឺមកវិញ។ ក្រុមគ្រួសារនោះនាំគ្នាសើច ហើយអង្គុយចុះមកជុំកង់ជុំវិញតុ រីក៏អង្គុយលើតុតែម្តង។ ពួកគេរៀបដាក់ចានម្ហូបចុះនាំគ្នាញ៉ាំលេងបណ្តើរ វេចខ្ចប់បាយនិងត្រីនឹងដៃបណ្តើរ។ សិដ្ឋអង្គុយឡើងត្រង់ខ្លួនភ្លឹង រង់ចាំប្រផ្នូលអាក្រក់មកដល់។

តើព្រលឹងរបស់កុល វីរៈបុត្រនឹងធ្វើយ៉ាងណាចំពោះកូនស្រី ប៉ុល ពតម្នាក់នេះ? តើគាត់នឹងបំបះតុឲ្យក្រឡាប់ រួចជះម្ហូបទៅលើនាងរឺ? តើគាត់នឹងបញ្ជូនមូសឲ្យមកខាំនាងទាល់តែធ្លាក់ខ្លួនឈឺរឺ? រីក៏គាត់នឹងបំផ្លាញសំណាងល្អរបស់នាងទាំងអស់ ទុកឲ្យអាពាហ៍ពិពាហ៍នាងត្រូវហិនហោច និងធ្វើឲ្យគ្រួសារថ្មីរបស់នាងលែងរាប់រកនាង?

រីក៏ព្រលឹងដ៏មានសណ្តានចិត្តម្នាក់នេះ គ្រាន់តែប្រាថ្នាចង់ឲ្យក្មេងក្មាងកម្ពុជាទាំងអស់អាចគេចផុត...ពីអតីតកាលបាន?

ល្ងាចនោះ សិដ្ឋស្រាប់តែមានអារម្មណ៍សន្តិ។ ពន្លឺស្ងប់ស្ងៀម និងស្រមោលជុំវិញហាក់ដូចជារឿងថ្មីមួយសម្រាប់នាង ចំនែកអារម្មណ៍របស់នាងចាប់ផ្តើមធូរស្រាលឡើងវិញ ដូចជាត្រូវមន្តអាគម។

នាងធុំក្លិនទឹកអប់នៃអារម្មណ៍ដ៏ផ្អែមល្ហែម និងភាពរឹងប៉ឹងក្នុងពេលតែមួយ។ សំឡេងចម្រៀងបន្លឺចេញពីម៉ាញ៉េអ្នកជិតខាងម្នាក់មកប៉ះនឹងដៃរបស់នាងថ្នមៗ។ ពាក្យចម្រៀងមួយម៉ាត់ៗកជាទំរង់ពន្លឺព្រះសូរិយានៅលើស្បែករបស់នាង។

ពន្លឺព្រះអាទិត្យនោះបន្លឺឡើងថា *គ្មាននរណាម្នាក់អាក្រក់ទេ ប៉ុន្តែពួកគេអាចក្លែងក្លាយ។*

*ក្លែងក្លាយ? យ៉ាងម៉េចទៅ?* សិដ្ឋសួរទាំងមិនស្តីមួយម៉ាត់ ដោយងឿងឆ្ងល់មែន។

និពន្ធដោយ៖ ជីអូហ្វ រីមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ *F*

ពន្លឺព្រះអាទិត្យនោះញញឹមបញ្ចេញធ្មេញប្រឡាក់របស់តាចាស់ម្នាក់។ *នាងដឹងច្បាស់ណាស់ថាវាយ៉ាងម៉េច។*

ខ្យល់ផាយផាត់ទៅមកនាំមកនូវក្លិនចំណីអាហារដ៏ឈ្ងុយឆ្ងាញ់។ ដើមឈើទាំងឡាយដកដង្ហើមវែងៗដោយពេញចិត្តពេញថ្លើម។

*ជីវិតគឺជារបស់ពិត។* សិដ្ឋឃើញចំហាយបាយ ហើរឡើងទៅក្នុងមែកឈើ។ *មរណៈគឺជារបស់ក្លែងក្លាយ។*

ពន្លឺព្រះអាទិត្យក្រោកឡើងបំរុងនឹងចាកចេញទៅ។ *ប្រាប់គាត់ទៅ។*

ពិភពលោកទាំងមូលបានមករកសភាពដើមវិញ។

នៅយប់នោះ ពេលដេកក្នុងអង្រឹងក្នុងបន្ទប់ជាមួយនឹងស្រីៗឯទៀត សិដ្ឋស្រាប់តែងើបអង្គុយភ្លាម។ ការពិតមិនព្រមឲ្យនាងដេកលក់នោះទេ។ នាងមើលឃើញថាគ្មានផ្លូវទៅមុខទៀតទេ។ នាងមិនអាចរៀបការជាមួយនឹងតារាបានទេ។ តើនាងម៉េចនឹងអាចសុំឲ្យគាត់រៀបការជាមួយនឹងមនុស្សម្នាក់ដែលធ្វើឲ្យបាត់បង់ជីវិតមនុស្សជាងមួយលាននាក់ទៅ? តើនាងម៉េចនឹងអាចពន្យល់ថា "ខ្ញុំត្រូវខ្មោចលង ពីព្រោះខ្ញុំជាកូនស្រីប៉ុល ពត ហើយខ្ញុំបាននិយាយកុហកនូវរឿងគ្រប់យ៉ាង" យ៉ាងនេះបានទៅ?

អ្នកដែលស្លាប់ទៅនឹងមិនព្រមឲ្យនាងរៀបការបានជាដាច់ខាត។ អ្នកដែលស្លាប់ទៅក៏នឹងមិនឲ្យនាងមានសេចក្ដីសុខដែរ។ បើអញ្ចឹងតើកូនស្រីប៉ុល ពតម្នាក់នេះអាចនឹងបួងសួងចំពោះនរណាទៅ? តើនាងអាចទៅសុំយោបល់ពីនរណាបាន?

នាងនិយាយខ្សឹបៗ *លោកគ្រូកុល វីរៈបុត្រ សូមបង្ហាញផ្លូវឲ្យខ្ញុំផង។*

ភាពងងឹតមានកម្លាំងខ្លាំងជាងពន្លឺព្រះអាទិត្យ។

វានិយាយថា *ដើម្បីក្លាយជាមនុស្សក្លែងក្លាយ ជាដំបូងនាងត្រូវកុហកខ្លួនឯង។*

តើសិដ្ឋបានប្រាប់រឿងកុហកអ្វីខ្លះ? នាងដឹងការពិត។ ឪពុករបស់នាងគឺជាប្រមុខរដ្ឋាភិបាលម្នាក់ដែលធ្វើទណ្ឌកម្ម និងសម្លាប់មនុស្សរាប់រយរាប់ពាន់នាក់ ព្រមទាំងធ្វើឲ្យប្រទេសជាតិទាំងមូលអត់ឃ្លានដោយសារតែការគ្រប់គ្រងខុស។ ខ្ញុំដឹងការពិត។

ខ្ញុំគ្រាន់តែមិនដែលគិតពីវាតែប៉ុណ្ណោះ។

ខ្ញុំមិនដែលប្រឈមមុខនឹងវាទេ។

*ការពិតវាខ្មៅងងឹតដូចជាខ្ញុំដូច្នោះដែរ ហើយនាងរស់នៅក្នុងខ្ញុំ ដែលជាភាពងងឹត។*

នាងធ្លាប់អានសៀវភៅ (និយាយឲ្យចំគឺអានតែជំពូកទីមួយនៃសៀវភៅ) ហើយក្រោយមកក៏ទម្លាក់សៀវភៅទាំងនោះចោលភ្លាមដូចជាម្រាមដៃនាងរលាកអញ្ចឹង។ គ្មានការពិតសំរាប់រូបនាងឡើយនៅក្នុងសៀវភៅអស់នោះ។ ការពិតដែលនៅរង់ចាំនាងខាងមុខប្រាកដជា ភាពឯកោ ភាពពេញវ័យប្រកបដោយទុក្ខសោក និងការដាក់ទារុណកម្មខ្លួនឯង។

*ឆាប់ធំឡើង។*

ជញ្ជាំងសន្លឹកត្នោតចាប់ផ្ដើមរង្គើដូចជាត្រូវខ្មោចធ្វើ។

ពេលជិះឡានក្រុងមកវិញ នាងមិននិយាយស្ដីអ្វីទាំងអស់។ តារាក៏ស្ងៀមស្ងាត់ដែរ ហើយឈ្ងោកមុខ។

នៅក្នុងបន្ទប់សណ្ឋាគារទទេដ៏ធំនោះ ភាពងងឹតកំពុងតែរង់ចាំនាង។ នាងបានឲ្យគេយកទូរស័ព្ទ និងទូរទស្សន៍ចេញពីបន្ទប់ទាំងអស់។ ស្នូរជើងរបស់នាងលាន់ឮដូចជាគ្មានវិញ្ញាណ។ ចូរ៉ានីនិងអ្នកបើកបរគឺជាមិត្តភក្តិតែពីរនាក់គត់របស់នាង។

នៅថ្ងៃបន្ទាប់នាងមិនទៅផ្សារសូរិយាទេ។ ផ្ទុយទៅវិញ នាងបែរជាទៅសារៈមន្ទីរទួលស្លែង។

ពួកម៉ូតូឌុបក្មេងៗមួយក្រុមរង់ចាំនៅក្រៅសណ្ឋាគារ ម្នាក់ៗពាក់មួកលេងកីឡាបាល់គប់។ សិដ្ឋបែរជាទៅហៅពូម៉ូតូឌុបរាងចាស់បន្តិច មុខមាត់ស្អាតបាត ដែលមានម៉ូតូកញ្ចាស់ ជិតចូលជាងមួយគ្រឿង។

ពេលដែលពួកគេបើកចេញទៅ នាងបានសាកសួរពីគ្រួសាររបស់គាត់។ គាត់រស់នៅតែម្នាក់ឯង ហើយគ្មានសាច់ញាតិណាទៀតក្រៅពីម្ដាយគាត់នៅកំពង់ធំនោះទេ។

នៅខាងក្រៅក្លោងទ្វារទួលស្លែង គាត់បាននិយាយ៖

- នេះគឺជាសាលាចាស់របស់ខ្ញុំ។

នៅក្នុងឈ្មៀងអគារមួយខ្នងមានបន្ទប់ជាជួរៗ ដែលមានគ្រែដែកនៅបន្ទប់នីមួយៗ ព្រមទាំងខ្នោះដៃ និងស្នាមឈាមនៅលើកំរាលឥដ្ឋ។ រូបថតលើជញ្ជាំងបង្ហាញឲ្យឃើញពីរាងកាយក្រញង់ៗជាប់ច្រវាក់នឹងគ្រែទាំងនោះ នៅពេលដែលពួកគេត្រូវបានរកឃើញនៅថ្ងៃរំដោះ។ នៅក្នុងរូបថតមួយ កៅអីមួយត្រូវធ្វើឲ្យដួលក្រឡាប់ ហាក់ដូចជាដោយសារតែការប្រញាប់ប្រញាល់។

សិដ្ឋដើរចេញមកក្រៅ ហើយសម្លឹងមើលទៅផ្ទះដ៏ស្រស់ស្អាតមួយខ្នងនៅទល់មុខផ្ទាល់។ វាគឺជាផ្ទះពណ៌សខ្ពស់មួយដូចផ្ទះនាងដែរ មានសសរស្ដម្ភ និងលានដំបូល ព្រមទាំងមានដាំរុក្ខជាតិត្រូពិចសមតែជាផ្ទះកូនស្រីអ្នកមានស៊ីវិល័យណាម្នាក់។ តើពួកគេនឹងគិតយ៉ាងណាពេលដែលអើតក្បាលមើលតាមលានដំបូលនោះ? តើពួកគេអាចរស់នៅទីនេះបានយ៉ាងដូចម្ដេចទៅ?

និពន្ធដោយ៖ ជីអូហ្វ រីមែន (Geoff Ryman)

ប្រែសម្រួលដោយ៖ *F*

វាលស្មៅត្រូវបានគេថែទាំងយ៉ាងល្អ ហើយពោរពេញទៅដោយបក្សីលោតផ្លោតៗ។ ពួកជាងកំពុងតែលាបបង្ហាបង្អួចគុកពណ៌ខៀវស្រស់លាយប្រផេះ។

នៅឯឈ្មៀងអគារកណ្ដាល គឺជាបន្ទប់ដាក់រូបថត។ មនុស្សនៅក្នុងរូបថតទាំងនោះសម្លឹងមើលមកនាងដូចជាមុខមនុស្សចេញពីម៉ាស៊ីនបោះពុម្ពរបស់នាងអញ្ចឹង។ តើមុខខ្លះដូចគ្នាដែររឺទេ?

- តើពួកគេជានរណា?- នាងទៅសួរអ្នកទេសចរជនជាតិខ្មែរម្នាក់។

- គឺពួកគេហ្នឹងឯង- ស្ត្រីម្នាក់នោះឆ្លើយតប។ - ទីនេះហើយជាកន្លែងដែលពួកគេបញ្ជូនក្រុមខ្មែរក្រហមដែលលែងមានប្រយោជន៍។ ពួកគេមិនខ្វះខ្វាយការដាក់ទណ្ឌកម្មទទេៗទៅលើជនជាតិខ្មែរធម្មតាៗនោះទេ។

មុខមនុស្សខ្លះគឺសុទ្ធតែជាមនុស្សប្រុសស្អាតៗ នៅក្មេងៗ។ ខ្លះទៀតជាកូនក្មេង និងជាស្ត្រីចំណាស់ៗ។

ស្ត្រីជាតិខ្មែរម្នាក់នោះដើរតាមនាង។ ដើរឲ្យបានជាគ្នារឺ? តើនាងទាយដឹងថាសិដ្ឋជានរណាហើយមែនទេ?

- ពួកគេមិនអាចវាយបក្សពួកមួយក្រុមៗឲ្យស្លាប់ទាំងអស់យ៉ាងស្រួលយ៉ាងហ្នឹងទេ។ ពួកគេបញ្ជូនពួកគេ ហើយនិងក្រុមគ្រួសារគេទាំងមូលមកទីនេះ។ មានទាំងកូនក្មេង និងយាយៗទៀតផង។ ពួកគេបានចែកថ្ងៃក្នុងសប្ដាហ៍នីមួយៗដោយឡែកក្នុងការសម្លាប់ក្មេងតូចៗ រឺក៏ប្រពន្ធ។

បុរសឥតទោសម្នាក់ញញឹមមកម៉ាស៊ីនថតយ៉ាងផ្អែមល្ហែម ដូចជាពូម៉ូតូឌុបនោះអញ្ចឹង ពោលគឺសម្លឹងចំមុខម៉ាស៊ីនថតរបស់អ្នកធ្វើទណ្ឌកម្មនោះតែម្ដង។ គាត់ហាក់ដូចជារំពឹងចង់បាននូវសណ្ដានចិត្តល្អ និងការសណ្ដោសប្រណីពីពួកគេ។ គាត់ហាក់ដូចជាចង់និយាយថា “សមមិត្ត”។

មុខនៅក្នុងរូបថតនោះស្រាប់តែមានចលនា។ គាត់បញ្ចេញស្នាមញញឹមកាន់តែធំឡើងៗ ហើយហៀបនឹងនិយាយ។

សិដ្ឋក៏គ្រលៀសភ្នែកចេញភ្លាម។ មុខមនុស្សបន្ទាប់ធ្វើឲ្យនាងដកដង្ហើមលែងចេញតែម្ដង។

នោះមិនមែនជាជនដែលនាងមិនធ្លាប់ស្គាល់នោះទេ។ នោះគឺជាមុខតារា គឺតារារបស់នាងដែលស្លៀកអាវ និងមួកកាតិបពណ៌ខ្មៅ។ នាងដង្ហក់ ហើយសម្លឹងមើលមកស្ត្រីនោះវិញ។ មុខដ៏រឹងប៉ឹងរបស់គាត់ងក់ចុះឡើង។ តើគាត់ជាខ្មោចដែររឺ?

សិដ្ឋដើរត្រេតត្រតទៅក្រៅដោយយកដៃខ្ទប់មុខ មិនដឹងថានាងអាចទ្រាំបានយូរប៉ុណ្ណាទៀតឡើយ។ ទឹកភ្នែកហូរស្រក់ចុះមុខរបស់នាង ចង់តែក្អួត ហើយនាងក៏បែរខ្នងដើម្បីកុំឲ្យគេមើលឃើញ។

និពន្ធដោយ៖ ជីអូហ្វ រ៉ៃមែន (Geoff Ryman)

ប្រែសម្រួលដោយ៖ *F*

បន្ទាប់មកនាងដើរទៅពូម៉ូតូឌុប ដែលកំពុងអង្គុយចាំនៅរោងមួយ។ ដោយគ្មានស្តីមួយម៉ាត់ នាងឡើងជិះម៉ូតូរបស់គាត់ ទាំងអារម្មណ៍ក្តៅក្រហាយនឹងកន្លែងនោះ ក្តៅក្រហាយនឹងរដ្ឋាភិបាល ដែលថែរក្សាកន្លែងនោះ ក្តៅក្រហាយនឹងពួកជនបរទេសដែលមកទស្សនាកន្លែងនោះប្រៀបដូចជាកន្លែងទាក់ទាញភ្ញៀវទេសចរ ពោលគឺក្តៅក្រហាយនឹងរឿងគ្រប់យ៉ាង។

*ពួកយើងមិនមែនជាមនុស្សបែបនោះទេ! ខ្ញុំមិនមែនជាមនុស្សបែបនោះទេ!*

ពូម៉ូតូឌុបនោះឡើងជិះម៉ូតូ រួចសិដ្ឋក៏សួរគាត់ថា៖ តើមានរឿងអ្វីកើតឡើងចំពោះគ្រួសាររបស់ពូ? វាគឺជាសំនួរដ៏ឃោរឃៅមួយ។ តែយ៉ាងណា គាត់ត្រូវតែញញឹម និងធ្វើទឹកមុខស្រស់ស្រាយ។ ឪពុករបស់គាត់ធ្លាប់បើកហាងតូចមួយ ក្រោយមកក៏ចេញទៅជនបទ ហើយក៏មិនដែលឃើញត្រលប់មកវិញទៀតដែរ។ គាត់ទៅរស់នៅជាមួយនឹងបងប្រុសនៅក្នុងមណ្ឌលជនភៀសខ្លួនមួយនៅក្នុងប្រទេសថៃ។ ពួកគេក៏បានត្រលប់មកប្រយុទ្ធនឹងវៀតណាមវិញ ហើយបងប្រុសគាត់ក៏ស្លាប់បាត់ទៅ។

នាងបំរុងនឹងប្រាប់ពូម៉ូតូឌុបថាឲ្យជូនទៅសណ្ឋាគារហ៊ីលតុនវិញ ប៉ុន្តែនាងស្រាប់តែមានអារម្មណ៍អាម៉ាស់មុខនឹងខ្លួនឯង។ ខ្លាចធ្វើអ្វីទៀត? តើនាងអាចរត់គេចបានឆ្ងាយប៉ុណ្ណា?

នាងក៏សុំឲ្យគាត់ជូននាងទៅផ្ទះចាស់របស់នាងនៅមហាវិថីមុនីវង្ស។

ខណៈពេលដែលម៉ូតូកំពុងតែបត់បែនចុះឡើងតាមផ្លូវលំ គេចគ្រលុកបណ្តើរ គេចអ្នកថ្មើរជើងបណ្តើរ នាងមានអារម្មណ៍ខឹងសម្បារនឹងឪពុករបស់នាង។ ម៉េចក៏គាត់ថ្លើមធំហ៊ាននាំនាងឲ្យជាប់ជំពាក់ជំពិននឹងរឿងបែបនេះ! សិដ្ឋធ្លាប់តែរស់នៅដូចកង្កែបក្នុងអណ្តូង មិនខ្វល់ពីរឿងរ៉ាវលើលោក ដូច្នេះនាងគិតថា៖ *វាប្រៀបដូចជានរណាម្នាក់លាបពណ៌សក់ឲ្យខ្ញុំ តែបែរជាជ្រុះសក់អស់ទៅវិញ។ វាប្រៀបដូចជានរណាម្នាក់ចោះត្រចៀករបស់ខ្ញុំ ធ្វើឲ្យឆ្លងមេរោគ ហើយត្រចៀករបស់ខ្ញុំទាំងមូលក៏ខូចប្រើការលែងបាន។*

នាងចាំថា នាងមិនដែលមានអារម្មណ៍អាណិតអាសូរចំពោះឪពុកនាងម្តងណាឡើយ។ នាងអាយុដប់ពីរឆ្នាំហើយ ពេលដែលគាត់ត្រូវគេកាត់ឲ្យជាប់ទោស។ គាត់ធ្វើជាចាស់ឈឺ ហើយដើរមិនត្រង់ជួរកាន់ឈើច្រត់។ អ្វីគ្រប់យ៉ាងដែលគាត់ធ្វើគ្រាន់តែជាការសម្តែងល្ខោនប៉ុណ្ណោះ។ នាងនៅចាំថា បានក្រឡិបក្រឡាប់ភ្នែកចុះឡើងដោយសេចក្តីអៀនខ្មាស ដែលមិនអាចនឹងលុបលាងចោលបាន។ មែនហើយ កាលគាត់ឈរនៅពីមុខថ្នាក់រៀនពោរពេញដោយកូនសិស្សគួរឲ្យស្រឡាញ់នោះ គាត់ដូចជាមិនអីទេ។ គាត់នៅអាចធ្វើឫកជាបងធំពួកគេបានទៀតផង។ ពួកគេទាំងអស់គិតថាគាត់ជាបណ្ឌិត។ ស្តាប់មើលគាត់និយាយគួរឲ្យពីរោះពិសា ដោយសារតែសំឡេងតូចឆ្មារដ៏ស្រទន់ តែលាក់ពុត

របស់គាត់ ហាក់ដូចជាគាត់ត្រូវគេបញ្ចូលសំឡេងដូច្នោះដែរ។ គាត់បានបង្ខំឲ្យសិដ្ឋអានកំណាព្យរបស់ករី រីវ៉ែឡេញ រីមប៊ីត និង រីលកេ។ គាត់បានសម្លាប់មនុស្សរាប់ពាន់នាក់ ដោយសារតែគេទទួលយកវប្បធម៌បរទេស។

*ខ្ញុំមិនដឹងថាខ្ញុំបានសាងកម្មអ្វីពីជាតិមុនទេបានជាសមនឹងបានលោកធ្វើជាឪពុក។ ប៉ុន្តែលោកមិនមែនជាឪពុករបស់ខ្ញុំកាលពីជាតិមុន ហើយជាតិមុខក៏អត់ដែរ។ ខ្ញុំបដិសេធលោកដោយដាច់អហង្ការ។ ខ្ញុំនឹងមិនដុតឈ្មោះឲ្យលោកជាដាច់ខាត។ ខ្ញុំនឹងធ្វើឲ្យលោកដើរអារាវ៉ាសែជុំវិញឋាននរកជារៀងរាល់ឆ្នាំដោយអត់ឃ្លានជារៀងរហូត។ ខ្ញុំនឹងបន់ស្រន់កុំឲ្យលោកចេញពីឋាននរកបានឲ្យសោះ។*

*ខ្ញុំមិនមែនជាកូនស្រីរបស់លោកទេ!*

*ប្រសិនបើលោកក្លែងក្លាយ ខ្ញុំត្រូវតែជា “ការពិត”។*

ក្រោមពន្លឺថ្ងៃថែស ផ្ទះចាស់របស់នាងមើលទៅដូចជាត្រូវគេបោះបង់ចោល។ នៅមាត់ជណ្តើរឡើងទៅ នាងបែរមក យកលុយដុល្លារមួយភ្ជាប់ដៃអោយទៅពូម៉ូតូឌុបនោះ។ នាងគិតមិនត្រង់ផ្លូវសោះ សូម្បីតែមើលក៏មិនត្រង់ផ្លូវដែរ។ ទស្សនវិស័យរបស់នាង ហាក់ដូចជាអាប់អួរអស់ហើយ។

នៅខាងក្នុង នាងដាក់កាតាបរូបខ្លាឃ្មុំចុះដោយស្ងប់អារម្មណ៍ ហើយឡើងទៅការិយាល័យរបស់នាង។ តុក្កតាយន្តអាយដូប្រញាប់ប្រញាល់សំដៅមករកនាង។ នាងបានធ្វើឲ្យវាបាក់ជើងក្រោយកាលដែលទាត់វាទម្លាក់ពីលើជណ្តើរ។ វាដើរប៉ាក់ប៉ឹកៗ យំញ៉េកៗដូចជាឆ្កែមែនទែន ព្រមទាំងបន្ទាបក្បាលដើម្បីឲ្យគេស្ទាប។

ពិតជាគួរឲ្យធូរទ្រូងមែន មានតែរូបមួយគត់នៅក្នុងធ្មេរម៉ាស៊ីនបោះពុម្ពរបស់នាង។

កុល វីរៈបុត្រសម្លឹងមើលមកនាង។ គាត់ជាបុរសវ័យកណ្តាលម្នាក់ រាងសង្ហា ស្លៀកខោអាវរញ៉េរញ៉ៃ តែប្រកបដោយគតិបណ្ឌិត។ ក្តីអាណិតអាសូរ និងមេត្តាធម៌បង្ហាញឲ្យឃើញនៅក្នុងភ្នែករបស់គាត់ទាំងគូ។

ទូរស័ព្ទចាប់ផ្តើមរោទិ៍។

- យល់ព្រម- នាងប្រាប់ពួកខ្មោច។

នាងលើកទូរស័ព្ទ ហើយរង់ចាំ។

បុរសម្នាក់និយាយ។

- ខ្ញុំឈ្មោះ យិន បូរ៉ា- សំឡេងរបស់គាត់គ្រលរៗ ហាក់ដូចជានិយាយក្នុងទឹក។

និពន្ធដោយ៖ ជីអូហ្វ រ៉ៃមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ F

មានពន្លឺភ្លឹបភ្លែតនៅក្នុងម៉ាស៊ីនបោះពុម្ព។ រូបថតមួយសន្លឹក បានរមៀលចេញមកយ៉ាងរហ័ស។ កូនសិស្សវ័យក្មេងម្នាក់សម្លឹងមើលមកនាងយ៉ាងសោមនស្សរីករាយ នៅក្នុងពិធីជប់លៀងលក្ខណៈគ្រួសារមួយ។ គេមានសក់ម៉ូតដូចពួកក្រុមតន្រ្តី ប៊ីតថល ហើយពាក់អាវឆ្នូតៗ។

- ហ្នឹងហើយជារូបខ្ញុំ- សំឡេងនៅនឹងទូរស័ព្ទបានបន្លឺឡើង។ - ខ្ញុំលេងបាល់ទាត់។

សិដ្ឋក្អក។ - តើចង់ឲ្យខ្ញុំធ្វើអ្វី?

- សរសេរឈ្មោះរបស់ខ្ញុំ- ខ្មោចនោះពោល។

- ចាំមួយភ្លែត- សិដ្ឋស្រដី ប្រៀបដូចជាត្រូវសណ្តំ។ នាងស្រវេស្រវារកប៊ិច រួចសរសេរនៅលើរូបថតនោះថា *យិន បូរ៉ា អ្នកទាត់បាល់*។ គេមើលទៅដូចជាសប្បាយ និងគួរឲ្យស្រឡាញ់ណាស់។ - ឯងគ្មាននរណាកាន់ទុក្ខឲ្យទេ- នាងទើបនឹងយល់។

- ពួកយើងគ្មាននរណាម្នាក់កាន់ទុក្ខអោយនោះឡើយ- ខ្មោចនោះនិយាយ។

បន្ទាប់មកស្រាប់តែមានសំឡេងដ៏គួរឲ្យខ្លាចមួយបន្លឺឡើងតាមទូរស័ព្ទ ប្រៀបដូចជាសំឡេងរាប់ពាន់ថ្ងូរឡើងព្រមៗគ្នា។

សិដ្ឋដាក់ទូរស័ព្ទចុះភ្លាម។ នាងឮសំឡេងបេះដូងនាងលោតក្អកក្អាក់ៗ ហើយគិតពីអ្វីដែលនាងត្រូវការ។ នាងដាក់ក្រដាសចុងក្រោយចូលទៅក្នុងម៉ាស៊ីនបោះពុម្ព។ ភ្លាមនោះវាស្រាប់តែបញ្ជូនរូបថតកាន់តែច្រើនចេញមក ហើយទូរស័ព្ទក៏រោទិ៍ម្តងទៀត។

នាងចេញទៅក្រៅ ហើយឃើញពូម៉ូតូឌុប ដែលកំពុងអង្គុយរង់ចាំនាងយ៉ាងអត់ធ្មត់។ នាងសុំអោយគាត់ទៅទិញក្រដាសសំរាប់ថតចម្លងពីរដុំ។ មុននឹងចេញទៅ នាងបន្ថែមថាឲ្យទិញប៊ិច ក្រដាសសម្រាប់សរសេរ និងឈើគូសបន្ថែមទៀត។ គាត់អោនក្បាល ញញឹម ហើយអោនក្បាលម្តងទៀតដោយសប្បាយចិត្តដែលរកបានម៉ូយម្នាក់។

នាងចូលទៅក្នុងវិញ ហើយលើកទូរស័ព្ទទាំងញ័រដៃ។

ក្នុងកំឡុងពេលកន្លះម៉ោងបន្ទាប់ នាងនិយាយទៅកាន់អ្នកដែលស្លាប់ រករូបថតពួកគេម្នាក់ៗហើយសរសេរឈ្មោះពួកគេលើនោះ។ ស្រ្តីម្នាក់យំសោករកកូនៗរបស់នាង។ សិដ្ឋរកឃើញរូបថតរបស់ពួកគេទាំងអស់ រួចដាក់ពួកគេនៅម្តុំជាមួយគ្នា មានឪពុកម្តាយ កូនបីនាក់ ពូមីង បងប្អូនជីដូនមួយ និងយាយតា ហើយបិតរូបពួកគេនៅនឹងជញ្ជាំងរបស់នាង។ គំនិតក្នុងការប្រជួបជុំក្រុមគ្រួសារទាំងឡាយក៏ដុះចេញឡើង។ នាងចាប់ផ្តើមបិតរូបថតដទៃទៀតទៅលើជញ្ជាំងរបស់នាង។

មានគេស្រែកហៅមកពីខាងក្រៅ ហើយពូម៉ូតូឌុបនៅចាំនៅនឹងមាត់ជណ្តើរ កាន់ក្រដាសផងប៊ិចផង។

និពន្ធដោយ៖ ជីអូហ្វ រ៉ៃមែន (Geoff Ryman)

ប្រែសម្រួលដោយ៖ *F*

- ខ្ញុំទិញសម្លខ្លះឲ្យនាង។

សម្លនោះដាក់នៅក្នុងថង់ឡើងណែន មើលទៅសុទ្ធតែបាយ និងព្រោន។ នាងអរគុណគាត់ ហើយឲ្យប្រាក់គាត់ដោយសមគួរ។ គាត់ញញឹមដាក់នាង រួចអោនក្បាលចុះឡើងម្តងហើយម្តងទៀត។

ពេញមួយល្ងាចនោះ រូបថតចេះតែចេញមករហូត។ ដល់ពេលព្រលប់ហើយ ទូរស័ព្ទនៅតែរោទិ៍ ឈ្មោះនៅតែត្រូវសរសេរ រហូតទាល់តែធ្វើឲ្យដៃរបស់សិដ្ឋឈឺយ៉ាងខ្លាំង ណាមួយមិនដែលធ្លាប់នឹងសរសេរអីផង។

កណ្តឹងនៅមុខផ្ទះស្រាប់តែរោទិ៍ ហើយនៅនឹងមាត់ជណ្តើរ ពូម៉ូតូឌុបលើកដៃសំពះ។

- ឲ្យខ្ញុំសុំទោស អ្នកនាង។ យប់ណាស់ទៅហើយ។ ខ្ញុំព្រួយបារម្ភនឹងអ្នកនាងណាស់។ តើខ្ញុំអាចទិញអាហារពេលល្ងាចជូននាងបានទេ?

សិដ្ឋទប់មិនញញឹមមិនបាន។ គាត់ព្រួយបារម្ភដូចជាម្តាយម្នាក់អញ្ចឹង។ ពួកគេពិតជាជំនាញណាស់ក្នុងការកសាងទំនាក់ទំនងជាមួយនឹងយើង រហូតទាល់តែយើងមិនអាចធ្វើអ្វីបានដោយគ្មានពួកគេ។ បើកាលពីមុនវិញ នាងច្បាស់ជាស្តីឲ្យគាត់ប៉ុន្មានម៉ាត់ ហើយដេញគាត់ទៅវិញមិនខាន។ តែឥឡូវនាងបញ្ជូនគាត់ចេញដោយមានបញ្ហា។

ហើយសរសេរទៀត។

នៅពេលដែលគាត់ត្រលប់មកវិញ ពូម៉ូតូឌុបមើលទៅដូចជាសប្បាយចិត្តណាស់។

- ខ្ញុំក៏បានទិញផ្លែឈើខ្លះឲ្យអ្នកនាងដែរ- គាត់បន្លឺឡើង ហើយបន្ថែមទាំងអៀនខ្មាសទៀតថា៖

- មិនបាច់ឲ្យប្រាក់ខ្ញុំក៏បានដែរ។

អ្វីម្យ៉ាងហាក់ដូចជារត់មកបុកសិដ្ឋ ហាក់ដូចជានាងកំពុងតែនៅលើម៉ូតូ ហើយនាងស្រាប់តែនិយាយទាំងមិនដឹងខ្លួនថា៖

- ចូលមកក្នុងមក។ ពិសាម្ហូបខ្លះដែរទៅ។

ពូម៉ូតូឌុបសំពះដោយក្តីដឹងគុណ ហើយពេលដែលគាត់ចូលទៅក្នុងភ្លាម ទូរស័ព្ទស្រាប់តែឈប់រោទិ៍។

ពួកគេអង្គុយរាបនឹងកម្រាលឥដ្ឋ។ គាត់ផ្អៀងក ហើយសម្លឹងមើលជុំវិញជញ្ជាំង។

- តើមនុស្សទាំងអស់នេះជាសាច់ញាតិរបស់អ្នកនាងរឺ?- គាត់សួរ។

នាងខ្សឹបប្រាប់វិញថា៖

- ទេ។ ពួកគេគឺជាខ្មោចដែលគ្មាននរណាគេកាន់ទុក្ខអោយ។

- ហេតុអ្វីបានជាពួកគេមករកនាង?- មាត់គាត់ច្រហូងដោយក្ដីងឿងឆ្ងល់។

- ដោយសារតែឪពុកខ្ញុំគឺ ប៉ុល ពត- សិដ្ឋនិយាយ ដោយគ្មានគិតអ្វីឡើយ។

ពូម៉ូតូឌុបនោះសំពះ។ - អូ្ហ!- គាត់ទំពាលេប រួចផ្ទៀងក្បាលគាត់ទៀត។ - ច្បាស់ជាយ៉ាប់ណាស់ហើយ។ នរណាៗក៏ស្អប់នាងដែរ។

សិដ្ឋចាប់អារម្មណ៍ថាទោះជានាងអង្គុយនៅកន្លែងណាក៏ដោយក្នុងបន្ទប់នេះ ភ្នែកទាំងឡាយនៅក្នុងរូបថតទាំងអស់នោះតែងតែសម្លឹងមើលមកនាងជាប់ជានិច្ច។ - ខ្ញុំមិនបានធ្វើអ្វីទាល់តែសោះ- សិដ្ឋនិយាយ។

- អ្នកនាងបានធ្វើរឿងខ្លះហើយតើ- ពូម៉ូតូឌុបតប។ គាត់ងក់ក្បាល ហើយក្រោកឈរឡើងព្រមទាំងដកដង្ហើមធំដោយក្ដីពេញចិត្ត។ ជីវិតពិតជាល្អណាស់ កាលបានឆ្អែតក្រពះ និងបានម៉ូយម្នាក់។ - ប្រសិនបើអ្នកនាងត្រូវការខ្ញុំ រកខ្ញុំនៅខាងក្រៅចុះ។

រូបថតមួយហើយមួយទៀត ឈ្មោះមួយហើយមួយទៀត។

យុគ អច្ឆរិយៈ៖ អ្នករាំ

ព្រឿង ឆាយ៖ នាយកសាលា

សរ កុធីតា អាយុ ៧ ឆ្នាំ ស្លាប់ដោយសារជម្ងឺហើម

សរ មករា ម្ដាយរបស់នាង (សរ កុធីតា) ជាគិលានុបដ្ឋាយិកា

ណាត់ មិត្តភាព ជាអ្នកបម្រើស៊ីវិល កើតពីត្រកូលអ្នកស្រែចំការ

ឆ មុន្នីរ័ត្ន៖ ប្រពន្ធវិស្វករទទួលបានពានរង្វាន់

យិន សុគន្ធា៖ មេស្រុកខ្មែរក្រហម។

នាងសម្លឹងមើលមុខទាំងអស់នោះ ហើយក៏យល់។ *តារា ខ្ញុំកំពុងតែធ្វើបែបនេះដើម្បីតារា*។

ទីក្រុងទាំងមូលនៅជុំវិញនាងស្ងប់ស្ងាត់ដូចចោរលួចសេះ ហើយនាងក៏ដឹងថាថ្មើរនេះយប់អធ្រាត្រណាស់ទៅហើយ។ យល់ល្អនាងគួរតែបញ្ជាក់ឲ្យប្រាកដក្នុងចិត្តថាតើពូម៉ូតូឌុបនោះទៅផ្ទះហើយរឺនៅ។

គាត់នៅតែរង់ចាំខាងក្រៅដដែល។

- បានហើយ។ ពូអាចទៅផ្ទះបាន។ តើពូរស់នៅឯណាដែរ?

គាត់ចង្អុលទៅខាងជើង។ - គឺនៅផ្លូវមុនីវង្សដូចជាអ្នកនាងដែរ។- គាត់សើចស្ទេញដោយនឹកឃើញថាខ្លួនមិនគួរយកផ្ទះខ្លួនមកប្រៀបធៀបនឹងផ្ទះនាងឡើយ។

គំនិតថ្មីមួយស្រាប់តែផុសឡើង។

- ថ្ងៃស្អែក តើពូអាចមកឲ្យព្រលឹមបន្តិចបានទេ? ហើយទិញម្ហូបផងទុកជប់លៀង? ត្រូវទិញត្រី អង្ករ បន្លែ សាច់ជ្រូក៖ ការី អាហារចៀន និងកាបាប់។

នាងឲ្យលុយគាត់យ៉ាងក្រាស់ក្រែល ហើយចុងក្រោយឈ្លេចសួរឈ្មោះរបស់គាត់។ ឈ្មោះគាត់មានន័យថាមាស។

- រាត្រីសួស្តី ពូសុវណ្ណ។

ពេញមួយយប់នោះ នាងធ្វើការយ៉ាងរហ័សរហួនដូចជាម៉ាស៊ីនឆ្លើយតបអញ្ចឹង។ នាងគិតថា នេះដូចជាការបោសសំអាតផ្ទះសំបែងមុនថ្ងៃបុណ្យទានដូច្នោះដែរ។ សម្លេងអ្នកដែលស្លាប់ហាក់ប្រែជាធម្មតា និងស្រដៀងៗគ្នា។ ហេតុអ្វីបានជាមនុស្សខ្លាចខ្មោច? ខ្មោចមិនអាចធ្វើបាបយើងបានទេ។ ខ្មោចគ្រាន់តែចង់បានអ្វីដែលយើងចង់បានប៉ុណ្ណោះ៖ យុត្តិធម៌។

មុខមនុស្សហូរហៀរពីជញ្ជាំងចូលដល់កាំជណ្តើរ យានដ្ឋាន ហើយនិងផ្ទះបាយ។ រូបនីមួយៗសុទ្ធតែមានឈ្មោះ។ នាងបានរកឃើញរឿងរ៉ាវគ្រួសាររបស់ចូរ៉ានីជាច្រើន ហើយក៏ភ្ជាប់សាច់ញាតិម្នាក់ៗទៅជាមែកធាងគ្រួសារ។

នាងសរសេររហូតដល់ភ្នែកមើលភ្លើងអគ្គិសនីបែកពណ៌ ធ្វើឲ្យនាងឡើងឈឺក្បាល។ នាងក៏សុំខ្មោចទាំងអស់នោះ៖

- សូមឲ្យខ្ញុំដេកសិនបានទេ?

ទូរស័ព្ទទាំងអស់ឈប់រោទិ៍ភ្លាម ហើយសិដ្ឋក៏ផ្តេកខ្លួនខ្ពោកទៅលើកំរាលឥដ្ឋធ្វើពីថ្លើមថ្មយ៉ាងប្រណីត។

នាងក្រោកឡើងទាំងមមឹងមមាំង នៅលើកំរាលឥដ្ឋនៅឡើយ។ ពន្លឺព្រះអាទិត្យចាំងចូលមកក្នុងបន្ទប់។ មុខនៅក្នុងរូបថតទាំងអស់នោះលែងមានស្នាមហើម រឺជាំទៀតហើយ។ មុខរបស់ពួកគេលែងចោទប្រកាន់ រឺសោកសង្រេងទៀតហើយ។ ពួកគេសុទ្ធតែញញឹមមករកនាង។ នាងស្ថិតនៅក្នុងចំនោមមិត្តភក្តិហើយ។

ម៉ាស៊ីនបោះពុម្ពបន្លឺសំឡេងឡើងចាប់ផ្តើមបោះពុម្ពបន្តទៀត។ ទូរស័ព្ទក៏ចាប់ផ្តើមរោទិ៍។ កណ្តឹងទ្វាររបស់នាងរោទិ៍ ហើយនាងឃើញសុវណ្ណ ព្រមទាំងប្រអប់មួយគំនរនៅឯកែបម៉ូតូគាត់ខាងក្រោយ។ គាត់ពាក់អាវដូចម្សិលមិញដែរ គឺអាវឡាកូសជជុះពណ៌ខៀវ។ មានស្នាមថ្មេរមួយនៅក្រោមដៃអាវ។ សិដ្ឋក៏ដឹងថា គាត់មានតែអាវហ្នឹងមួយគត់។ នាងនឹកឃើញដល់គាត់បោកគក់អាវនេះនឹងចានដែកជារៀងរាល់យប់។

និពន្ធដោយ៖ ជីអូហ្វ រីមែន (Geoff Ryman)

ប្រែសម្រួលដោយ៖ *F*

សិដ្ឋ និងសុវណ្ណរំកិលតុធំៗទៅជិតបង្អួចខាងមុខ។ សិដ្ឋយកក្រណាត់ទ្រាប់តុថ្លៃៗរបស់នាងចេញមកប្រើជាលើកដំបូង ព្រមទាំងចានប្រាក់ផងដែរ។ សំណែនត្រូវបានរៀបចំឡើងដូចជាថ្ងៃបុណ្យចូលឆ្នាំថ្មីអញ្ចឹង។ សុវណ្ណបានទិញក្រដាស និងប៊ិចថែមទៀត។ គាត់ដឹងថាត្រូវការរបស់ទាំងនេះសម្រាប់ធ្វើអ្វីហើយ។

- ខ្ញុំអាចជួយបាន អ្នកនាង។

គាត់ក៏បានទៅសាលានឹងគេនឹងឯងដែរ ហើយគាត់អាចសរសេរអក្សរបានយ៉ាងស្អាត តាមរបៀបបុរាណ។ គាត់ និងសិដ្ឋ ពួកគេទាំងពីរនាក់ក៏ជួយគ្នាប្រកបឈ្មោះអ្នកដែលចែកឋាន ហើយដុតចោល។

- ខ្ញុំក៏ចង់សរសេរឈ្មោះក្រុមគ្រួសារខ្ញុំដែរ- គាត់ស្រដី។ គាត់ដុតឈ្មោះទាំងនោះចោលទាំងខ្សឹកខ្សួល។

ក្លិនដ៏ឈ្ងុយឈ្ងប់ភាយឡើងទៅលើ។ ខ្យល់អាកាសជុំវិញពោរពេញទៅដោយសំឡេងដំណកដង្ហើមចូល។ កំទេចក្រដាសដែលដុតមិនអស់ហោះហើរទៅតាមវាយោផាយផាត់ដែរ។ សល់ផេះពេញធុង ប៉ុន្តែទោះជាធ្វើការអស់កន្លះថ្ងៃក្តី ក៏សិដ្ឋ និងពូម៉ូតូឌុបនោះឧទ្ទិសជូនបានត្រឹមតែពាក់កណ្តាលនៃចំនួនឈ្មោះទាំងអស់ប៉ុណ្ណោះ។

- រាត្រីសួស្តី ពូសុវណ្ណ- នាងប្រាប់គាត់។

- អ្នកនាងបានបញ្ជូនកុសលច្រើនណាស់- សុវណ្ណស្រដី ដោយគ្រាន់តែចង់គួរសមប៉ុននោះ។

សិដ្ឋគិតថា *នោះបើខ្ញុំមានបុណ្យកុសលដែលត្រូវធ្វើមែន*។

ពេលគាត់ចេញទៅ ម៉ាស៊ីនបោះពុម្ពក៏ចាប់ផ្តើមដំណើរការបន្តទៀត ព្រមទាំងទូរស័ព្ទផងដែរ។ នាងធ្វើការពេញមួយយប់ ទាល់តែអស់ក្រដាសជុំទីពីរទើបឈប់។

រូបចុងក្រោយគឺរូបលោក កុល វីរៈបុត្រ។

*តារា* នាងសន្យានឹងខ្លួនឯង។ *ត្រូវទៅជួបតារា*។

នៅពេលព្រឹក នាងក៏ទូរស័ព្ទហៅគាត់។

- តើពួកយើងអាចជួបគ្នានៅពេលបាយថ្ងៃត្រង់ ដើម្បីដើរលេងនៅមាត់ទន្លេបានទេ?

សិដ្ឋរង់ចាំនៅកំពូលជញ្ជាំងធ្វើពីថ្លើមថ្ម គយគន់តាចាស់ម្នាក់កំពុងនេសាទត្រីនៅក្នុងទន្លេសាប ហើយស្រាប់តែឃើញថានាងស្រឡាញ់ប្រទេសខ្លួនឯងណាស់។ នាងស្រឡាញ់ប្រជាជនទាំងឡាយដែលរឹងប៉ឹង មិនដែលចេះត្អូញត្អែរ តែញញឹមជាប់ជានិច្ច ណាមួយពួកគេមិនដែលចង់ធ្វើបាបនាង

ឡើយ  ទោះបីជាគ្រួសារនាងបានធ្វើទុក្ខទោសដល់ពួកគេយ៉ាងណាក្តី។  តើពួកអ្នកទាំងអស់គ្នាដឹងថាមានកូនស្រីបិសាចម្នាក់កំពុងអង្គុយនៅក្នុងចំនោមអ្នករាល់គ្នាទេ?

ភ្លាមនោះរឿងតែម្យ៉ាងគត់ដែលសិដ្ឋចង់បានគឺក្លាយជាមនុស្សម្នាក់ក្នុងចំនោមពួកគេដែរ។ ព្រះសង្ឃនៅព្រះពន្លា  អ្នករត់ការពាក់អាវពណ៌សរត់ត្របាញ់ទៅណាមកណី  ជនខ្វិលច្រអូសគងជើងយោលទៅវិញទៅមក ប្រុសក្មេងៗស្លៀកពាក់ដូចអ្នករ៉េបអាមេរិច ដើរលក់របស់គួរឲ្យសង្ស័យ មិនដឹងជាថ្នាំញៀន រឺស្រោមអនាម័យ។

នាងឃើញតារាដើរយឺតៗសំដៅមករកនាង។ គាត់ពាក់អាវថ្មីរបស់គាត់ ហើយញញឹមមកនាង ប៉ុន្តែមើលទៅ គាត់មិនដូចជាធូរស្រាលប៉ុន្មានឡើយ។ ពួកគេខានជួបគ្នាអស់ពីរថ្ងៃហើយ។ គាត់ដឹងថាមានបញ្ហាអ្វីមួយហើយ  ដឹងថានាងមានរឿងអ្វីមួយត្រូវប្រាប់គាត់។  គាត់បានទិញម្ហូបអាហារថ្ងៃត្រង់យកមកញ៉ាំជុំគ្នាខ្ចប់ក្នុងប្រអប់តូចមួយ។ សិដ្ឋគិតថា នេះប្រហែលជាពេលចុងក្រោយហើយ។

ពួកគេផ្តោះប្តូរការស្វាគមន៍គ្នាទៅវិញទៅមក ស្ទើរតែដូចបងប្អូនជីដូនមួយ។ គាត់អង្គុយក្បែរនាង ហើយញញឹម។ សិដ្ឋសើចដោយភ័យខ្លាចនឹងពាក្យដែលនាងបំរុងនឹងនិយាយ។

តារាសួរដោយងឿងឆ្ងល់៖

- តើមានអ្វីគួរឲ្យសើចទៅ?

នាងមិនអាចឈប់សើចនោះទេ។

- គ្មានអ្វីគួរឲ្យចង់សើចទេ។ គ្មានអីទេ។

នាងដកដង្ហើមវែងៗ ដើម្បីបញ្ឈប់ តែសេចក្តីតក់ស្លុតចេះតែសម្រុកមករកនាង ធ្វើឲ្យនាងផ្ទុះសំណើចម្តងទៀត។

- ខ្ញុំបានកុហកបង។ កុល វីរៈបុត្រមិនមែនជាឪពុកខ្ញុំទេ។ អ្នកនយោបាយម្នាក់ទៀតទេទើបជាឪពុករបស់ខ្ញុំ។ ជននោះបងក៏ធ្លាប់ឮដែរ...

រឿងទាំងមូលពិតជាគួរឲ្យភ័យខ្លាច   និងឆ្គាំឆ្គងខ្លាំងណាស់ដែលធ្វើឲ្យសំណើចចាប់ច្របាច់នាងជាប់យ៉ាងណែនក្នុងកណ្តាប់ដៃ បណ្តាលឲ្យនាងនិយាយអ្វីលែងចេញ។ នាងសើច ហើយយំក្នុងពេលតែមួយ។ តារាសម្លឹងមើលមិនដាក់ភ្នែក។

- ឪពុករបស់ខ្ញុំឈ្មោះ សាឡុត ស។ នោះគឺជាឈ្មោះពិតរបស់គាត់។- ទោះជាយ៉ាងណា នាងនៅតែមិនអាចជំរុញឲ្យខ្លួនឯងនិយាយឈ្មោះនោះបាន។  នាងអាចប្រាប់ពូម៉ូតូឌុបបាន  ប៉ុន្តែម៉េចក៏ប្រាប់តារាមិនបាន? នាងក៏បង្ខំខ្លួនឯងឲ្យនិយាយ។

- ឪពុករបស់ខ្ញុំគឺប៉ុល ពត។

ស្ងាត់ឈឹង។

តារាអង្គុយស្ងៀមធ្មឹងនៅក្បែរនាង។ មនុស្សម្នាដើរហើរទៅមកកាត់មុខពួកគេ ទូកបុកនឹងដីភឹបៗពេលឡើងចំណត។

មួយសន្ទុះក្រោយមក តារាក៏បន្លឺឡើង៖

- បងដឹងថាអូនកំពុងតែធ្វើអ្វីហើយ។

ដូចជាមិនត្រូវទេ។

- ធ្វើអ្វី? តើបងចង់មានន័យថាម៉េច?

តារាប្រែទឹកមុខជូរចត់ ព្រមទាំងខឹង។

- ណ្ហើយៗ។

គាត់អង្គុយ បែរមុខចេញពីនាង។ សំណើចរបស់សិដ្ឋស្រាប់តែញ័ររបបូតដល់ឈប់។

- បងប្រាប់អូនហើយថាគ្រួសារបងចេះដឹងខុសត្រូវណាស់- គាត់និយាយតិចៗ។

- គ្រួសាររបស់បងគួរឲ្យស្រឡាញ់ណាស់!- សិដ្ឋលាន់មាត់។

ថ្គាមរបស់គាត់សង្កៀតចូលគ្នា។

- ពួកគេក៏មានសំណួរខ្លះអំពីអូនដែរ អូនដឹងទេ?

- ខ្ញុំមិនយល់ទេ។

គាត់ធ្វើភ្នែកក្រឡិបក្រឡាប់ រួចគ្រវាសភ្នែកមកមើលនាងវិញ។

- មានវិធីងាយស្រួលជាងហ្នឹង ប្រសិនបើចង់បែកគ្នាជាមួយនឹងនរណាម្នាក់នោះ។

គាត់ក្រោកឈរឡើងក្រោស ហើយដើរចេញទៅទាំងមិនបែរក្រោយ ទុកឲ្យនាងអង្គុយនៅលើជញ្ជាំងនោះតែម្នាក់ឯង។

នៅមាត់ទន្លេ នរណាៗក៏មានសិទ្ធិស្មើគ្នាដែរ។ យុវជនក្មេងៗសណ្តូកខ្លួនលើជញ្ជាំង ម្តាយកំសត់ដឹកដៃកូន ជនបរទេសដើរទៅមកយ៉ាងទាន់ហន់ ធ្វើរាងហាក់ដូចជាចង់ប្រាប់គេថាអត់បានយកលុយមកជាប់ខ្លួននោះទេ។ យុវនារីធាត់ៗបីនាក់ច្រានប្រលែងគ្នាសើចសប្បាយស្ទើរតែធ្វើឲ្យបាក់បង់អង្គុយ។

សិដ្ឋមិនដឹងថាត្រូវធ្វើយ៉ាងម៉េចនោះទេ។ នាងកំរើកមិនរួចទេ។ ក្តីអស់សង្ឃឹមបានសង្កត់ខ្លួននាង ធ្វើឲ្យក្បាលនាងវិលវល់អស់ហើយ។

*ខ្ញុំបាត់បង់គាត់ហើយ។*

និពន្ធដោយ៖ ជីអូហ្វ រ៉ៃមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ *F*

ពន្លឺព្រះអាទិត្យហាក់ដូចជាបន្ទាបខ្លួនមកក្បែរនាង ចំនាំងរបស់វានៅលើទឹករង្កើរន្ទើនៗពេលទូកជិះកាត់ម្ដងៗ។

*ទេ នាងមិនបានបាត់បង់គាត់ទេ។*

ទឹកទន្លេមានក្លិនព្រួយបារម្ភយ៉ាងកក់ក្ដៅ។ សំឡេងចរាចរណ៍ទង្គិចនឹងការអត់ធ្មត់។

*មិនទាន់នៅឡើយទេ។*

គ្មានការអត់អោនឡើយនៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែតែងមានអព្ភូតហេតុកើតឡើងបន្តបន្ទាប់នូវការអាណិតអាសូរ និងការទទួលយក។

សិដ្ឋពេញចិត្តនឹងទទួលយកនូវអព្ភូតហេតុនោះ។ ពូម៉ូតូឌុបទិញសម្លឲ្យនាង។ នាងសម្រេចចិត្តផ្ញើសេចក្ដីទុកចិត្តរបស់នាងទៅលើអព្ភូតហេតុហើយ។

សិដ្ឋនិយាយទៅកាន់ពន្លឺព្រះអាទិត្យដោយមិនបញ្ចេញសំឡេងឡើយ។ *លោកតាវីរៈបុត្រ។ អរគុណហើយ។ តាបានប្រាប់ខ្ញុំនូវរឿងគ្រប់យ៉ាងដែលខ្ញុំត្រូវការដឹង។*

សិដ្ឋក្រោកឈរឡើង ស្រាប់តែឃើញពូម៉ូតូឌុប មិនដឹងជាមកតាំងពីអង្កាល់។ គាត់បានឌុបនាងទៅកាន់ហាងលក់ទូរស័ព្ទហេឡូ។

តារាមិនព្រមសម្លឹងមើលនាងនោះទេ។ គាត់ប្រញាប់ដើរទៅដើរមកពីក្រោយតុគិតលុយនោះទោះបីជាគ្មានការអ្វីត្រូវធ្វើក៏ដោយ។ សិដ្ឋនិយាយទៅកាន់គាត់ដូចជាអតិថិជនម្នាក់អញ្ចឹង។

- ខ្ញុំចង់ទិញទូរស័ព្ទដៃមួយគ្រឿង- នាងពោល តែគាត់មិនព្រមឆ្លើយទេ។ - មានមនុស្សម្នាក់ដែលខ្ញុំត្រូវនិយាយជាមួយ។

អតិថិជនម្នាក់ទៀតបានដើរចូលមក។ នាងក៏ជាកូនស្រីដ៏ស្រស់ស្អាតម្នាក់ដែរ ហើយគាត់បម្រើនាង ដោយធ្វើអាការៈយ៉ាងគួរសម។ គាត់សរសើររូបរាងរបស់នាង។

- និយាយមែនណា៎! នាងពិតជាមើលទៅឡូយណាស់។

នារីម្នាក់នោះមើលទៅហាក់សប្បាយចិត្តណាស់។ កែវភ្នែករបស់តារាគ្រលៀសមកមើលសិដ្ឋមួយភ្លែត។

សិដ្ឋអង្គុយរង់ចាំលើកៅអី។ ឥឡូវនេះគឺជាផ្ទះរបស់នាងទៅហើយ។ តារាមិនរវល់នឹងនាងឡើយ។ នាងយកទូរស័ព្ទចេញមក ហើយតេទៅលេខរបស់គាត់។ គាត់លើកទូរស័ព្ទដាក់ត្រចៀកហើយនិយាយថា៖

- ទៅផ្ទះទៅ។

- បងនេះហើយគឺជាផ្ទះរបស់ខ្ញុំ- នាងតប។

គាត់យកមេដៃចុះប៊ូតុង C ។

នាងរង់ចាំបន្តទៀត។ ស្រមោលថ្ងៃកាន់តែវែងឡើងៗ។

- ពួកយើងបិទហាងហើយ- គាត់និយាយ ដោយឈរនៅនឹងមាត់ទ្វារ ទាំងមិនមើលមុខនាង។

ដោយអាម៉ាស់មុខ សិដ្ឋអោនគេចពីគាត់ ចេញទៅតាមទ្វារបាត់ទៅ។

នៅក្រៅផ្សារសូរិយា ពូម៉ូតូឌុបកំពុងលេងបោះគ្រប់ឡុកឡាក់ជាមួយនឹងមិត្តភក្តិគាត់។ គាត់ក្រោកឈរឡើង។

- ពួកគេនិយាយថា ខ្ញុំពិតជាសំណាងណាស់ដែលបានកូនស្រីប៉ុល ពតធ្វើជាម៉ូយ។

ក៏គ្មានការសម្ងាត់នៅក្នុងប្រទេសកម្ពុជាដែរ។ សិដ្ឋយល់ថា អ្នករាល់គ្នានឹងដឹងអស់ហើយនាពេលនេះ។

នៅឯផ្ទះ ក្រដាសបោះពុម្ពទាំងដុងៗកំពុងតែរង់ចាំនាង។ សិដ្ឋញ៉ាំអាហារត្រជាក់ ដែលទុកចោល។ វាគ្មានរសជាតិទាល់តែសោះ។ ទូរស័ព្ទចាប់ផ្ដើមរោទិ៍។ នាងដេកលក់ទាំងទូរស័ព្ទនៅដាក់នឹងត្រចៀកនៅឡើយ។

នៅថ្ងៃបន្ទាប់ សិដ្ឋត្រលប់ទៅផ្សារសូរិយាទៀត ដោយយកប្រអប់ក្រដាសបោះពុម្ពមួយប្រអប់ទៅផង។

នាងទម្លាក់ប្រអប់នោះទៅលើតុគិតលុយធ្វើពីប្លាស្ទិចពណ៌ខៀវរបស់ក្រុមហ៊ុនទូរស័ព្ទហេឡូ។

- ដោយសារតែខ្ញុំជាកូនស្រីប៉ុល ពត- នាងប្រាប់តារា ព្រមទាំងកាន់រូបថតប៉ុន្មានសន្លឹកហុចឲ្យគាត់មើល។ - ជនរងគ្រោះដែលគ្មានគេកាន់ទុក្ខឲ្យទាំងអស់បានបោះពុម្ពរូបថតរបស់ពួកគេដោយប្រើម៉ាស៊ីនបោះពុម្ពរបស់ខ្ញុំ។ នែ៎! មើលទៅ។ ទាំងនេះសុទ្ធតែជារូបមនុស្សដែលបានបាត់បង់មនុស្សជាទីស្រឡាញ់របស់ខ្លួន ហើយគ្មាននរណាម្នាក់នៅចាំពួកគេឡើយ។

នាងឃើញថាថ្ពាល់កំពុងតែញ័រ ហើយនាងមិនអាចកាន់ក្រដាសទាំងនោះជាប់នឹងដៃទៀតទេ។ ក្រដាសនោះធ្លាក់ពីចេញពីដៃនាង ប៉ុន្តែនាងឈរមកក្រោយវិញ ដៃទាំងពីរក្រព័ទ្ធចូលគ្នា។

តារាលុតជង្គង់ចុះ ហើយរើសក្រដាសទាំងអស់នោះ ទាំងទឹកមុខម៉ឺងម៉ាត់ និងស្ងាត់ស្ងៀម។ គាត់សម្លឹងមើលមុខមួយចំនួន។ សិដ្ឋរុញកាតពណ៌បៃតងរួញឡើងទក់មកឲ្យគាត់មើល។ គឺជាអត្តសញ្ញាណបណ្ណរបស់ក្រុមគ្រួសារនាង។

គាត់មើលអត្តសញ្ញាណបណ្ណនោះ។ ដោយក្ដីគោរពយ៉ាងខ្លាំង គាត់បានរៀបរូបថតទាំងអស់នោះដាក់លើតុគិតលុយវិញជាមួយនឹងអត្តសញ្ញាណបណ្ណយ៉ាងប្រុងប្រយ័ត្នជាទីបំផុត។

- ទៅផ្ទះទៅ សិដ្ឋ- គាត់ស្រដី ប៉ុន្តែមិនមែនសោះកក្រោះដូចមុនទេ។

និពន្ធដោយ៖ ជីអូហ្វ រ៉ៃមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ *F*

- ខ្ញុំនិយាយហើយថា- នាងចាប់ផ្តើមនិយាយដោយសេចក្តីក្តៅក្រហាយ ប៉ុន្តែក្រោយមកក៏មិនអាចនិយាយទៀតបាន។ -ខ្ញុំប្រាប់បងហើយ។ បងទៅដល់ទីណាផ្ទះខ្ញុំនៅទីនោះ។

- បងជឿអូនឯងហើយ- គាត់តប ដោយមើលទៅជើងខ្លួន។

- អញ្ចឹង...- សិដ្ឋរកនឹកពាក្យអ្វីនិយាយមិនចេញឡើយ។

- វាមិនអាចទៅរួចទេ សិដ្ឋ- គាត់តប។ គាត់រៀបចំក្រដាសបោះពុម្ពមួយដុងនោះឲ្យមានសណ្តាប់ធ្នាប់។ -តើអូនបំរុងនឹងធ្វើអីជាមួយនឹងរូបថតទាំងអស់នេះ?

អ្វីម្យ៉ាងធ្វើឲ្យនាងនិយាយថា៖

- តើបងនឹងធ្វើយ៉ាងម៉េចជាមួយនឹងរូបថតទាំងអស់នេះ?

ទឹកមុខរបស់គាត់ប្រែប្រួលដោយក្តីមន្ទិល។

- នេះក៏ជាប្រទេសរបស់បងដែរ។ តើបងចង់ធ្វើអ្វី? អ្ហូ! ខ្ញុំដឹងហើយ បងគឺជាជនកម្សត់ម្នាក់មកពីគ្រួសារក្រីក្រមួយ តើមាននរណាទៅសុំបងឲ្យធ្វើអ្វីបានទៅ? តែបងនៅមានសាច់ញាតិទាំងអស់ តែមនុស្សជាច្រើនគ្មានសូម្បីតែម្នាក់។ ហើយបងអាចទិញអាវថ្មីៗបាន ឯអ្នកខ្លះរកតែអាវមួយពាក់នឹងគេក៏មិនចង់បានផង។

តារាលូកដៃទាំងពីរចេញមក ហើយក៏សើច។

- យ៉ាងម៉េចហ្នឹង សិដ្ឋ?

*សិដ្ឋកំពុងតែចោទខ្ញុំថាចិត្តកំណាញ់រឺ?*

- បងក៏ត្រូវតែធ្វើអ្វីម្យ៉ាងដែរ- សិដ្ឋចង្អុលទៅកាន់ក្រដាសទាំងអស់នោះ ពោលគឺមុខទាំងនោះ។ -តើបងគិតថាខ្មោចនឹងមិនតាមនិយាយជាមួយនឹងបងដែរទេរឺ?

ភ្នែកពួកគេសម្លឹងមើលគ្នាមិនដាច់។ នាងប្រាប់គាត់ពីអ្វីដែលគាត់អាចធ្វើបាន។

- ខ្ញុំគិតថា បងគួរតែរៀបចំការតាំងពិព័រណ៍មួយ។ ខ្ញុំគិតថាក្រុមហ៊ុនទូរស័ព្ទហេឡូគួរតែឧបត្ថម្ភកម្មវិធីនេះ។ បងទៅប្រាប់ពួកគេចុះ។ បងប្រាប់ពួកគេថា កូនស្រីរបស់ប៉ុល ពតចង់ធ្វើការផ្លាស់ប្តូរមួយចំនួន ហើយបានជ្រើសរើសពួកគេ។ ប្រាប់ពួកគេទៅថា ពួកខ្មោចបាននិយាយជាមួយខ្ញុំតាមទូរស័ព្ទដៃក្រុមហ៊ុនរបស់ពួកគេ។

នាងបង្វែរខ្លួនកន្លះជុំ រួចដើរចេញទៅ។ នាងទុករូបថតទាំងនោះនៅនឹងគាត់។

នាយប់នោះ នាង និងពូម៉ូតូឌុប រៀបចំសំណែនមួយទៀត ហើយដុតឈ្មោះគ្មានអ្នកកាន់ទុក្ខដែលនៅសល់ប៉ុន្មាន។ មាននៅសល់ឈ្មោះរាប់ពាន់ឯណោះ។

នៅថ្ងៃបន្ទាប់ នាងបានត្រលប់ទៅហាងក្រុមហ៊ុនទូរស័ព្ទហេឡូម្តងទៀត។

និពន្ធដោយ៖ ជីអូហ្វ រ៉ៃមែន (Geoff Ryman)

ប្រែសម្រួលដោយ៖ *F*

- ខ្ញុំក៏បានកុហករឿងមួយទៀតដែរ- នាងប្រាប់តារា។ នាងយករបាយការណ៍ពីគ្រូទាយជាច្រើនមក។ នាងបានប្រាប់ពីអ្វីដែលគ្រូទាយរបស់ ហ៊ុន សែន បានប្រាប់នាង។ - មង្គលការនេះពិតជាមានភាពចម្រុងចម្រើនជាពិសេស។

- តើពិតទេ?- ទឹកមុខគាត់ស្រងូតស្រងាត់។

- បងមិនគួរជឿពាក្យគ្រប់ម៉ាត់ដែលខ្ញុំនិយាយនោះទេ លុះត្រាតែខ្ញុំធ្វើឲ្យបងជឿទុកចិត្តសិន។ អញ្ចឹងទៅរកគ្រូទាយឲ្យគេទាយដោយខ្លួនឯងចុះ។ លើកនេះបងជាអ្នកចេញលុយខ្លួនឯង។

មុខរបស់គាត់នៅស្ងៀមធ្មឹង រីឯភ្នែកគាត់សម្លឹងចុះក្រោយសឹងនឹងធ្លុះកំរាលឥដ្ឋទៅហើយ។ បន្ទាប់មក គាត់ក៏ងើយឡើង សម្លឹងមើលចំភ្នែករបស់នាង។ - បងនឹងទៅ។

នេះហើយជាលើកដំបូងក្នុងជីវិតសិដ្ឋ ដែលនាងចង់សើចចំពោះរឿងអ្វីម្យ៉ាងដែលមិនមែនជាសេចក្ដីភ័យខ្លាចរបស់នាង។ នាងចង់សើចដោយក្ដីរីករាយ។

- តើយើងអាចទៅញ៉ាំអាហារថ្ងៃត្រង់នៅឡាក់គីសេវ៉ែនបានទេ?- នាងសួរ។

- ប្រាកដជាបាន- គាត់តប។

ទូរស័ព្ទទាំងអស់នៅក្នុងហាងនោះស្រាប់តែរោទិ៍ឡើងព្រមៗគ្នា។

បទភ្លេងគ្រប់បែបគ្រប់បទបន្លឺឡើងព្រមៗគ្នា។ តារាឈរស្រឡាំងកាំង។ ចុងក្រោយ គាត់ក៏លើកទូរស័ព្ទមួយគ្រឿង យកមកដាក់នឹងត្រចៀក។

- គឺសម្រាប់អូន- គាត់ស្រដី ហើយហុចទូរស័ព្ទឲ្យនាង។

គ្មានឈ្មោះរឺក៏លេខនៅលើអេក្រង់នោះទេ។

សំឡេងដ៏កក់ក្ដៅមួយបានបន្លឺឡើង៖

- *សូមជួយអបអរសាទរ កូនស្រីសម្លាញ់។*

- នរណាគេហ្នឹង?- សិដ្ឋសួរ។ មានឈ្មោះមិនច្រើនទេដែលនាងចាំ។

លោកកុល វីរៈបុត្រឆ្លើយ៖

- *គឺឪពុកថ្មីរបស់ឯង។*

ឮសូរសំឡេងខ្យល់។

- *ខ្ញុំទទួលស្គាល់ឯងហើយ។*

សំឡេងរាប់រយរាប់ពាន់និយាយឡើងព្រមៗគ្នា៖

- *ពួកយើងទទួលស្គាល់ឯងហើយ។*

នៅក្នុងប្រទេសកម្ពុជា មនុស្សចែកផ្ទះនៅជាមួយខ្មោច ដូចដែលគេនៅជាមួយនឹងធូលីដីដែរ។ អ្នកឮសំឡេងខ្មោចដើរសសៀរតាមជំហានជើងនីមួយៗរបស់អ្នក។ អ្នកអាចបោសសំអាតចេញ ប៉ុន្តែសំឡេងនោះនឹងមិនទៅណាឆ្ងាយឡើយ។

នៅចុងត្របែកនៃមហាវិថីព្រះមនុរីវង្ស មានផ្ទះមួយខ្នងដែលម្ចាស់បានឲ្យទៅខ្មោចកាន់កាប់។ អ្នកអាចសាកទៅបិទទ្វារមុខផ្ទះ។ ប៉ុន្តែនៅថ្ងៃបន្ទាប់ទ្វារនោះនឹងរបើកឡើងដដែល។ អ្នកក៏អាចសាកដំដែកគោលបំបិទទ្វារនោះ ដូចដែលអ្នកជិតខាងធ្លាប់បានសាក។ វានៅតែរបើកឡើងវិញដដែល។

នៅពេលថ្ងៃ តែងតែមានមនុស្សប្រាំប្រាំមួយនាក់កំពុងរង់ចាំចង់ចូលទៅក្នុង រឺក៏នៅឈរវេរាខាងក្រៅ ព្រោះតែខ្លាច។ នៅខាងក្រៅមានសុទ្ធតែសំណែនផ្កាឈូក រឺក៏ដូងដោយមានដោតធូបក្រអូបពីលើ។

ជញ្ជាំង និងគ្រប់ជាន់ថ្នាក់ រហូតដល់ពិតាន សុទ្ធតែពោរពេញទៅដោយរូបថត។ នៅតាមសាឡុង ផ្ទះបាយ កាំជណ្ដើរ ការិយាល័យ បន្ទប់ដេកទំនេរ មានសុទ្ធតែរូបថតចិនខ្មែរ នៅពិធីរៀបអាពាហ៍ពិពាហ៍ មន្ត្រីរាជការខ្មែរទទួលទានអាហារជាលក្ខណៈគ្រួសារនៅខាងក្រៅ ជនជាតិចាមនៅក្រៅព្រះវិហាររបស់ពួកគេ ជនជាតិវៀតណាមកំពុងកាន់ត្រីដែលគេចាប់បាន ក្មេងប្រុសតូចៗទៅសាលារៀនដោយស្លៀកខោខ្លី អ្នកធាក់ស៊ីក្លូនៅពីមុខយានហួសសម័យដ៏ចម្លែករបស់ពួកគេ ប្រពន្ធនៅតាមតូបកំពុងកូរសម្ល។ ពួកគេទាំងអស់គ្នាសុទ្ធតែសប្បាយរីករាយ ហើយផ្ទៃខាងក្រោយនៃរូបថតទាំងអស់នោះគឺទីក្រុងភ្នំពេញនៅពេលដែលទីក្រុងនេះជាទីក្រុងដ៏ស្រស់ស្អាតបំផុតប្រចាំអាស៊ីអាគ្នេយ៍។

រូបថតទាំងអស់សុទ្ធតែមានឈ្មោះសរសេរនៅពីលើ ជាក្បាច់អក្សរបុរាណ។

នៅលើតុមានឈ្មោះរាប់ពាន់បោះពុម្ពចេញមកលើក្រដាសជាច្រើនសន្លឹក។ នៅក្បែរតុនោះមានឈើគូស និងធុងដាក់ផេះ និងទឹក។ ការប្រតិបត្តិនោះមានលក្ខណៈសាមញ្ញធម្មតា។ គ្រាន់តែត្រូវដុតឈ្មោះ ហើយឧទ្ទិសកុសលផលបុណ្យឲ្យទៅអ្នកដែលចែកឋានទៅ តែគ្មាននរណាកាន់ទុក្ខឲ្យ។

នៅជាប់នោះ គឺសញ្ញាតូចមួយដែលសរសេរជាភាសាអង់គ្លេសថា HELLO ។

នៅរៀងរាល់បុណ្យភ្ជុំបិណ្ឌម្ដងៗ ឈ្មោះទាំងអស់នោះត្រូវបានបញ្ជូនទៅកាន់វត្តអារ៉ាមទូទាំងក្រុង។ មាសក្រដាសត្រូវបានគេសង្កត់បិតទៅលើសន្លឹកក្រដាសនីមួយៗ ហើយយកទៅភ្ជាប់នឹងបាយបិណ្ឌមួយដុំៗ។ នៅម៉ោង ៨ ព្រឹក គេយកអាហារទៅប្រគេនព្រះសង្ឃ មានបាយនិងត្រីហុយក្ដៅៗព្រមជាមួយនឹងសម្លៀកបំពាក់ថ្មីៗផងដែរ។ នៅម៉ោង ១០ ព្រឹក គេយកអាហារបន្ថែមទៀតទៅចែកចាយដល់ជនពិការ និងជនក្រីក្រ។

និពន្ធដោយ៖ ជីអូហ្វ រីមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ F

ហើយស្ទើរតែរាល់ព្រឹក គេឃើញកូនស្រីកម្ពុជាដ៏ស្រស់ស្អាតម្នាក់ដើរលេងតាមកន្លែងប្រសព្វរវាងទន្លេសាប និងទន្លេមេគង្គ។ ដូចជាប្រទេសកម្ពុជាដែរ នាងតែងស្រឡាញ់ចូលចិត្តអ្វីដែលទំនើប។ នាងស្លៀកពាក់ខោអាវម៉ូតថ្មីបំផុត។ នាងស្តាប់ចម្រៀង R&B របស់កម្ពុជា។ នាងឈប់មើលម្តងម្កាលនូវសំណង់ថ្មីៗនៅមាត់ទន្លេ ខ្លះត្រូវសាងសង់ដោយរន្ទា ខ្លះទៀតត្រូវបានពង្រីកដោយម៉ាស៊ីនស្ទូច។ នាងទិញគុយទាវពីអ្នកលក់មុខមិនស្រស់ ដែលប្រើចង្ក្រានតូចៗសម្រាប់រកស៊ី។ នាងកាន់សៀវភៅមួយក្បាល រីក៏អង្គុយនៅលើជញ្ជាំងធ្វើពីថ្មើមថ្មដើម្បីសរសេរអក្សរ ហើយនិងគយគន់ទូក ពពកមូសុង ហើយនិង ពួកម៉ូតូឌុប ។ នាងនិយាយជាមួយនឹងចំនាំងព្រះអាទិត្យនៅលើទឹកទន្លេ ហើយហៅថា “ពុក” ។

និពន្ធដោយ៖ ជីអូហ្វ រ៉ៃមែន (Geoff Ryman)
ប្រែសម្រួលដោយ៖ *F*